00374873

**Declassified to Public**
**12 April 2013**

D130/9/6

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ ២៦)

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង ធីរិទ្ធ

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០០៩

**ឯកសារដើម**
**DOCUMENT RECEIVED/DOCUMENT REÇU**
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 10 / SEP / 2009
ម៉ោង (Time/Heure): 11:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA.Fuy

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ តុលាការ សម្ងាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន: សម្ងាត់ (បណ្ដោះអាសន្ន)

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី ប្រឆាំងនឹង "ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម" ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩**

---

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់លោក អៀង ធីរិទ្ធ**

លោក ផាត់ ពៅសៀង

[illegible]

**ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម**
**CERTIFIED COPY/COPIE CERTIFIÉE CONFORME**
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 11 / SEP / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA.Fuy

**មេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និង**
**ដើមបណ្ដឹងរដ្ឋប្បវេណីគ្មានតំណាងទាំងអស់**

<u>ផ្ញើជូន៖</u>

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គីមសាន

ចៅក្រម ន័យ ធុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Katinka LAHUIS

ចៅក្រម Rowan DOWNING

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក William SMITH

# មាតិកា

II សេចក្តីផ្តើម និងកាលប្បវត្តិ....................................................................៤

II អង្គហេតុពាក់ព័ន្ធ និង នីតិវិធី.................................................................៥

២.១ អង្គហេតុពាក់ព័ន្ធ.....................................................................៥

២.២ បណ្តឹងឧទ្ធរណ៍........................................................................៨

III យុត្តាធិការពិនិត្យលើបណ្តឹងឧទ្ធរណ៍.................................................៩

IV សំណើសុំសវនាការផ្ទាល់មាត់...........................................................១២

V បទដ្ឋានច្បាប់ពាក់ព័ន្ធ..............................................................................១២

៥.១ ច្បាប់កម្ពុជា.........................................................................................១២

៥.២ ច្បាប់អន្តរជាតិ.....................................................................................១៣

VI មូលហេតុទី ១ នៃបណ្តឹងឧទ្ធរណ៍: ការរំលោភលើការជំនុំជម្រះក្តីដោយយុត្តិធម៌..........១៨

VII មូលហេតុទី ២ នៃបណ្តឹងឧទ្ធរណ៍: មាត្រា ១៥០: អញ្ញត្រកម្មមិនត្រូវដាក់កម្រិតចំពោះការធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងឡើយ.............................................២០

VIII មូលហេតុទី ៣ នៃបណ្តឹងឧទ្ធរណ៍ : ការបកស្រាយប្រឆាំងនឹង "ន័យធម្មតា".............២១

៨.១ ស្មារតីរបស់ច្បាប់ តទល់នឹង តួអក្សររបស់ច្បាប់..................................២១

៨.២ ម្ចាស់ចម្លើយសារភាព គឺមិនពាក់ព័ន្ធ......................................................២៤

IX មូលហេតុទី ៤ នៃបណ្តឹងឧទ្ធរណ៍: អញ្ញត្រកម្មនៃមាត្រាទី ១៥ ត្រូវតែអនុវត្ត........២៥

X មូលហេតុទី ៥ នៃបណ្តឹងឧទ្ធរណ៍: ការហាមឃាត់ដាច់ខាតចំពោះការប្រើប្រាស់ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម...............................................................២៦

XI មូលហេតុទី ៦ នៃបណ្តឹងឧទ្ធរណ៍: ការបកស្រាយសន្និសញ្ញាដោយមិនត្រឹមត្រូវ....២៨

XII មូលហេតុទី ៧ នៃបណ្តឹងឧទ្ធរណ៍: ទ្រឹស្តីនៃភស្តុតាងដែលបានមកដោយអំពើទុច្ចរិត.២៩

XIII មូលហេតុទី ៨ នៃបណ្តឹងឧទ្ធរណ៍: មិនអនុញ្ញាតឲ្យសំអាងលើខ្លឹមសារនៃចម្លើយសារភាព

១៣.១ ឧឡារិករណ៍មិនត្រឹមត្រូវ................................................................៣២

១៣.២ ភាពមិនអាចជឿទុកចិត្តបានរារាំង កសចស មិនឲ្យសំអាងលើខ្លឹមសារ........៣៣

00374875



XIV មូលហេតុទី ៩ នៃបណ្តឹងឧទ្ធរណ៍: ការដាក់កម្រិតនៃការប្រើប្រាស់ចំណារ និងប្រូចត្តិរូប....................................................................................................៣៥
XV មូលហេតុទី ១០ នៃបណ្តឹងឧទ្ធរណ៍: នៅពេលណា/ដោយនរណា ដែលការធ្វើទារុណកម្ម បានកើតឡើង គឺមិនជាប់ពាក់ព័ន្ធទេ.....................................................................៣៥
XVI មូលហេតុទី ១១ នៃបណ្តឹងឧទ្ធរណ៍: ការបកស្រាយមិនត្រឹមត្រូវនៃឧស្សនទាននៃមាត្រា ១៥..............................................................................................................................៣៦
XVII មូលហេតុទី១២ នៃបណ្តឹងឧទ្ធរណ៍:ភាពអនុវត្តបាននៃគោលការណ៍ *In Dubio Pro Reo* ..................................................................................................................................៤០
XVIII មូលហេតុទី ១៣ នៃបណ្តឹងឧទ្ធរណ៍: កសចស ពុំមានសិទ្ធិបង្កើតច្បាប់នោះទេ.......៤១
XIX មូលហេតុទី ១៤ នៃបណ្តឹងឧទ្ធរណ៍: ដីកាសម្រេចពុំមានមូលហេតុគ្រប់គ្រាន់.......៤២
XX សេចក្តីសន្និដ្ឋាន..................................................................................................៤៣
VI សំណូមពរ.........................................................................................................៤៤

00374876



## I សេចក្ដីផ្ដើម និង ភាពប្បវត្តិ

1. ក្រុមមេធាវីការពារក្ដីអ្នកស្រី អៀង ធីរិទ្ធ ("**ជនត្រូវចោទ**") នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៩ បានដាក់"សំណើរបស់ខ្លួន សុំច្រានចោលភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម" ("**សំណើសុំរបស់មេធាវីការពារ**")[1] ។ កសព នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩ បានដាក់ "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់មេធាវីការពារក្ដី អៀង ធីរិទ្ធ សុំច្រានចោលភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៩ ("**ចម្លើយតបរបស់ កសព**") ដែលបានជូនដំណឹងទៅភាគីទាំងអស់នៅមួយសប្ដាហ៍ក្រោយមក ពោលគឺនៅថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០០៩[2] ។ នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ មេធាវីការពារក្ដីបានដាក់ចម្លើយតបរបស់ខ្លួនចំពោះ "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់មេធាវីការពារក្ដី អៀង ធីរិទ្ធ សុំច្រានចោលភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម" ("**ចម្លើយតប**")[3] ។ ការិយាល័យសហចៅក្រមស៊ើប ("**កសចស**") នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០៩ បានចេញដីកាសម្រេច "លើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ("**ដីកា**")[4]។

2. ក្រុមមេធាវីការពារក្ដីជនត្រូវចោទ អៀង ធីរិទ្ធ នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៩ បានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី អៀង ធិរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស លើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩[5] ទៅ កសចស ដោយបានជូនដំណឹងអង្គជនុំជម្រះសាលាដំបូង និងភាគីនានារបស់មេធាវីការពារក្ដី អំពីគោលបំណងប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

[1] សំណើ"សំណើរបស់មេធាវីការពារសុំច្រានចោលភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារ D130 ។

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះសំណើរបស់មេធាវីការពារ សុំច្រានចោលភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ចុះថ្ងៃទី ១១ កុម្ភៈ ២០០៩, ៣០ មេសា ២០០៩, ឯកសារលេខ D130/5 ។

[3] ចម្លើយតបរបស់មេធាវីការពារក្ដីចំពោះ "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់មេធាវីការពារក្ដី អៀង ធីរិទ្ធ សុំច្រានចោលភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម" ចុះថ្ងៃទី ១៨ ឧសភា ឆ្នាំ ២០០៩, ឯកសារ D130/6។

[4] កសចស ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ (ជូនដំណឹងនៅថ្ងៃទី ២៩ ខែ កក្កដា ២០០៩), ឯកសារ D130/8 ។

[5] សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី អៀង ធិរិទ្ធ ប្រឆាំងនឹងដីការបស់ កសចស លើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៩, ឯកសារ D130/9 ។

00374877



លើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម។ មេធាវីការពារក្តីនៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ បានដាក់ "សំណើជាបន្ទាន់របស់មេធាវីការពារស្នើសុំពន្យាពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង "ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម"[6]។ ភាគីពីរផ្សេងទៀតមិនបានឆ្លើយតបចំពោះសំណើនេះឡើយ។ អង្គបុរេជំនុំជម្រះបានអនុញ្ញាតលើសំណើសុំពន្យាពេលវេលាកំណត់នេះ នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩[7]។

3. មេធាវីការពារដាក់ក្តីសូមដាក់បណ្តឹងឧទ្ធរណ៍នេះ ស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ។

## II អង្គហេតុ និង នីតិវិធីពាក់ព័ន្ធ

### ២.១ អង្គហេតុពាក់ព័ន្ធ

4. នៅក្នុងសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ខ្លួន កសព បានយោងទៅលើចម្លើយសារភាពជាច្រើន និងឯកសារដទៃទៀត ដែលស្ថិតនៅក្រោមលក្ខណៈវិនិច្ឆ័យនៃភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម[8]។ កសព ក៏បានសំអាងលើឯកសារជាច្រើន ដែលឯកសារទាំងនោះយោងទៅលើភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម[9] ។ ម្យ៉ាងវិញទៀត ឯកសារដទៃទៀតដែលប្រើ

---

[6] សំណើជាបន្ទាន់របស់មេធាវីការពារស្នើសុំពន្យាពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង "ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩, ឯកសារ D130/9/1។

[7] សេចក្តីសម្រេចលើសំណើសុំរបស់មេធាវីការពារក្តី ស្នើសុំពន្យាពេលវេលាកំណត់ សម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៩, ឯកសារ D130/9/2 ។

[8] សូមមើលសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អក្សរក្នុងយោងលេខ 80, 82, 119, 177-180, 182, 183, 203, 216, 327, 335, 337, 340, 342, 344, 345, 350, 355-357, 375, 376, 384, 391-394, 398-400, 410, 416, 417, 419, 420, 425, 427, 429, 432, 433, 457-463, 465-467, 490, 519, 520, 528, 530-533, 537-539, 541, 552, 555, 558, 564 និង 566 ។

[9] សូមមើលសៀវភៅរបស់លោក Stephen Heder និង Brian D. Tittemore ក្រោមចំណងជើងថា "បេក្ខជនប្រាំពីរនាក់សម្រាប់ជំនុំជម្រះទោស: ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម" (Seven Candidates for Prosecution. Accountability for the Crimes of the Khmer Rouge ), ភ្នំពេញ: DC-Cam 2004 ទំព័រ ២៩-៣១។ សូមមើលផងដែរ សៀវភៅរបស់លោក David Chandler, Ben Kiernan និង Chanthou Boua ក្រោមចំណងជើងថា "ប៉ុល ពត ធ្វើផែនការ

ដោយ កសព យោងទៅលើប្រភពបន្ទាប់បន្សំ[10]។ ហេតុដូច្នេះ កសព បានប្រើប្រាស់ទ្រនាប់នៃភស្តុតាងជាច្រើននៅក្នុងសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ខ្លួន ដែលយោង និងសំអាងទៅលើចម្លើយសារភាព ដែលទទួលបានមកដោយការធ្វើទារុណកម្ម។

5. ចាប់តាំងពីថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៨ ការយកចម្លើយ ឌុច ដោយ កសចស មាននៅក្នុងសំណុំរឿងលេខ ០០១ បានដាក់បញ្ចូលទៅក្នុងសំណុំរឿងលេខ ០០២[11]។ ដោយផ្អែកលើការយល់ដឹងដោយផ្ទាល់របស់គាត់ ការយកចម្លើយទាំងនេះបានចែងពីការជឿជាក់របស់គាត់ដែលថា ចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ ត្រូវបានធ្វើឡើងដោយការធ្វើទារុណកម្ម[12] ហើយថាមន្ទីរសន្តិសុខដទៃទៀតក៏បានអនុវត្តវិធីសាស្ត្រយកចម្លើយសារភាពស្រដៀងគ្នានេះដែរ[13]។ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ នៅក្នុងអំឡុងពេលដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឌុច បានបញ្ជាក់ពីជំនឿនេះ។ ជាការឆ្លើយតបចំពោះសំនួររបស់ចៅក្រម Lavergne ឌុច បានឆ្លើយថា:

> [...] ខ្ញុំមិនដែលជឿថា ចម្លើយដែលខ្ញុំទទួលបានស្របនឹងការពិតទេ។ យ៉ាងច្រើនណាស់បាន ៤០ ភាគរយប៉ុណ្ណោះ ។ [...]

---

អនាគត់: ឯកសារសំងាត់របស់កម្ពុជាប្រជាធិបតេយ្យ" (Pol Pot Plans the Future) ។ សូមមើលសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទំព័រ ១០៦ អក្សរក្នុងលេខយោង ៨០ ។

[10] ឧទាហរណ៍សូមមើល ព្រឹត្តិប័ត្រ ខឺភ្នំពេញប៉ុស (16/1) "បងធំទី២ របស់ អាមេនី" ចុះផ្សាយថ្ងៃទី ១២-២៥ ខែ មករា ២០០៧ (ERN 00081516-00081520 )។

[11] *ព្រះរាជអាជ្ញា តទល់ជាមួយ នួន ជា និងអ្នកដទៃទៀត..* សំណុំរឿងលេខ 002/19-09-2007-អវតក-អបជ(០២)ç, កំណត់ហេតុ នៃការសួរតទល់ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ ឯកសារ D86/1 ឯកសារនេះដាក់នៅក្រឡាបញ្ជីនៅថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៨ (ERN 00145454-00145457) ។

[12] ឧទាហរណ៍ សូមមើលកំណត់ហេតុយកចម្លើយជនត្រូវចោទ ថ្ងៃទី៧ ខែសីហា ២០០៧ ឯកសារ D86/3 (ERN 000147517 -000147527) ទំព័រ ៨, សូមមើលកំណត់ហេតុយកចម្លើយជនត្រូវចោទ ថ្ងៃទី ២ តុលា ឆ្នាំ ២០០៧ D86/6 (ERN 000147600-000147608) ទំព័រ ៦ ។ល។

[13] ឧទាហរណ៍ សូមមើលកំណត់ហេតុយកចម្លើយជនត្រូវចោទ ថ្ងៃទី២ ខែ មិថុនា ២០០៨ ឯកសារ D87 (ERN 00195571-00195579) ទំព័រ ៤ ដែលក្នុងកំណត់ហេតុស្តាប់ចម្លើយនេះ ឌុច ថ្លែងថា "គណៈអន្តេវ្រ្តីយ៍ទាំងមូលបានដឹងថា ការធ្វើទារុណកម្មត្រូវបានអនុវត្តនៅគ្រប់មន្ទីរសន្តិសុខទាំងអស់" ។

[14] ប្រតិចារិត ចុះថ្ងៃទី ៧ មេសា ២០០៩ សំណុំរឿង ០០១ **ឯកសារលេខ** E1/9.1, ទំព័រ 22 (បន្ទាត់ 4-6, 10-12 និង 16-17 ។

ដូច្នេះ ចម្លើយដែលខ្ញុំទទួលបានអំពីបែបណាក៏ដោយ យ៉ាងច្រើនបានពិតត្រឹម ៤០%។ [...] ប៉ុន្តែមនុស្សដែលគេឆ្លើយដាក់យ៉ាងច្រើនពិតត្រឹម ២០% ។ [...] ប៉ុន្តែ គ្មានស្អីជាការផ្ទឹមប្រៀបដើម្បីយល់ប៉ុន្មានភាគរយច្បាស់ទេ[14] ។

6. នៅសវនាការនាថ្ងៃបន្ទាប់ បន្ទាប់ពីបានគិតត្រឡប់ក្រោយច្រើនថែមទៀត ឌុច កាត់បន្ថយភាគរយនៃការពិតដែលមាននៅក្នុងចម្លើយសារភាពមកត្រឹមតែ ២០% តែប៉ុណ្ណោះ។ គាត់បាននិយាយថា ៖

ខ្ញុំនៅតែទទួលថា សេចក្តីសារភាពដែលយើងខ្ញុំទទួលបានមិនស្របនឹងការពិតទាំងស្រុងទេ យ៉ាងច្រើនណាស់ ២០ ភាគរយ យ៉ាងច្រើនណាស់ ២០ ភាគរយហ្នឹង យ៉ាងច្រើនម្ភៃភាគរយនៃខ្លឹមសារដែលឆ្លុះបញ្ចាំងពីការពិតនោះ។ [...] អាម្ភៃភាគរយដែលខ្ញុំតែងតែនិយាយ ថាជាសេចក្តីសារភាពវាមិនដែលពិត ពិព្រោះវាខុសពីស្ថានភាពពិត[15]។

7. អង្គហេតុពាក់ព័ន្ធមានចែងនៅក្នុងសំណើ និងចម្លើយតបរបស់មេធាវីការពារក្តី។ ដោយផ្អែកលើឯកសារទាំងនេះ និងចម្លើយតបរបស់ កសព, កសចស បានចេញដីការបស់ខ្លួនសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ដែលក្នុងដីកានោះបានលើកឡើង នៅក្នុងចំណោមបញ្ហាដទៃទៀត ដូចខាងក្រោម:

- កសចស ជាអ្នកទទួលខុសត្រូវក្នុងការស្វែងរកឲ្យឃើញថា តើភស្តុតាងបានមកដោយការធ្វើទារុណកម្មដែរ ឬយ៉ាងណា ។
- អញ្ញត្រកម្មនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម (CAT) ដាក់កម្រិតតែនៅពេលណាមានបញ្ហានៃការធ្វើសក្ខីមកលើខ្លួនឯង ជាពិសេស ការហាមឃាត់ការប្រើប្រាស់ចម្លើយសារភាពដែលដិតដាមដោយការធ្វើទារុណកម្ម ប្រឆាំងនឹងជនរងគ្រោះនៃអំពើទារុណកម្ម ឬប្រឆាំងនឹងជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ដោយជនរងគ្រោះនៃអំពើទារុណកម្ម ។
- មាត្រា ១៥ នៃអនុសញ្ញា CAT អនុវត្តស្មើៗគ្នាចំពោះជនដែលជាប់ចោទពីបទប្រព្រឹត្តអំពើទារុណកម្ម តាមរយៈទម្រង់នៃការទទួលខុសត្រូវដោយផ្ទាល់ ។
- ស្មារតីរបស់ច្បាប់មិនត្រូវបិទបាំងដោយតួអក្សររបស់ច្បាប់នោះទេ។ ការអនុវត្តអញ្ញត្រកម្មនៃមាត្រា១៥ នៃ CAT នៅក្នុងករណីនេះ នឹងមិនអាចរារាំងជនដែលរងនៃ

[15] ប្រតិចារិត ចុះថ្ងៃទី ៨ មេសា ២០០៩ សំណុំរឿង **ឯកសារលេខ** E1/10.1, ទំព័រ 105 (បន្ទាត់ 8-11, 10-12, ទំព័រ 106 បន្ទាត់ 20-21) ។

អំពើទារុណកម្មនៅពេលអនាគតបានដែរ។ ម្យ៉ាងវិញទៀត កសចស បានបញ្ជាក់ថា បញ្ហានៃភាពដែលអាចគួរឲ្យជឿជាក់បាននៃភស្តុតាង នឹងមិនកើតមានទេ ។

- មានរបៀបពីរ (២) ដែលភស្តុតាងត្រូវបានដិតដាមដោយការធ្វើទារុណកម្ម អាចប្រើប្រាស់ (១) ជាភស្តុតាងតំរុយនៃការស៊ើបអង្កេតនិង(២) ជាភស្តុតាងដើម្បីបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជា បានប្រើប្រាស់ព័ត៌មាននៅក្នុងចម្លើយសារភាព។
- នៅដំណាក់កាលនេះ គេមិនអាចនិយាយថា ចម្លើយសារភាពមិនមានធាតុផ្សំនៃការពិតនោះនៅឡើយទេ ។ អាស្រ័យហេតុនេះ កសចស នឹងកំណត់ពីភាពអាចគួរឲ្យជឿជាក់បាននៃចម្លើយសារភាពនីមួយៗនៅក្នុងសំណុំរឿង តាមមួយករណីៗនៅពេលបញ្ចប់នៃកិច្ចស៊ើបសួរ ។

## ២.២ បណ្ដឹងឧទ្ធរណ៍

8. មេធាវីការពារក្ដីសូមលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានខកខានក្នុងការពិចារណាឲ្យបានត្រឹមត្រូវទៅលើក្របខណ្ឌច្បាប់ជាតិ និងច្បាប់អន្តរជាតិ និងបានជ្រើសរើសយកវិធីសាស្ត្រមិនត្រឹមត្រូវ និងបានអនុវត្តវិធីសាស្ត្រមិនត្រឹមត្រូវក្នុងការសម្រេចថា តើភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការប្រើប្រាស់មធ្យោបាយធ្វើទារុណកម្ម អាចយកមកពិចារណានៅដំណាក់កាលស៊ើបអង្កេត និងដាក់បញ្ចូលនៅក្នុងដំណើរការនីតិវិធី។ វាជាវិធានដ៍មានសារៈសំខាន់នៃច្បាប់អន្តរជាតិដែលថា ភស្តុតាងដែលបានមកដោយមធ្យោបាយនេះ គឺត្រូវតែច្រានចោល ដោយមិនគិតដល់សក្តានុពល ភាពត្រឹមត្រូវ និងភាពអាចជឿទុកចិត្តបានរបស់វានោះទេ ដើម្បីឆ្លុះបញ្ចាំងពីការស្អប់ខ្ពើមរបស់ជាតិសាសន៍ដែលស៊ីវីល្បៃចំពោះការប្រើប្រាស់វិធីសាស្ត្រដែលឃោឃៅបែបនេះ។ មេធាវីការពារក្ដីសូមលើកឡើងថា ការប្រើប្រាស់ភស្តុតាងដែលបានមកដោយខុសច្បាប់បែបនេះ មិនអាចទទួលយកនៅក្នុងដំណើរការនីតិវិធីបច្ចុប្បន្នបានទេ ដោយសារតែវាត្រូវបានឃាមឃាត់យ៉ាងច្បាស់ដោយច្បាប់លក្ខន្តិកៈ និង យុត្តិសាស្ត្រ។

9. ម្យ៉ាងវិញទៀត ការប្រើប្រាស់ភស្តុតាងបែបនេះ គឺរំលោភលើសិទ្ធិទទួលបានការជំម្រះក្ដី និងសច្ចធារណ៍នៃទោសរបស់ជនត្រូវចោទ។ នៅក្នុងកាលៈទេសៈបែបនេះ មេធាវីការពារក្ដីយល់ឃើញថា កសចស មិនគួរអនុញ្ញាតឲ្យមានការប្រើប្រាស់ភស្តុតាងដែលឡាយណា ដែលត្រូវបានកំណត់ដោយបុគ្គល ឬដោយការសំអាងថា ជាភស្តុតាងបានមកតាមរយៈការធ្វើទារុណកម្ម នោះទេ។

## III យុត្តាធិការពិនិត្យលើបណ្តឹងឧទ្ធរណ៍

10. មេធាវីការពារក្តីដាក់បណ្តឹងឧទ្ធរណ៍នេះស្របតាមវិធាន ៥៥(១០) និងវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង និងស្របតាមគោលការណ៍ជាសារវ័ន្ត ដែលមានចែងនៅក្នុងវិធាន ២១ ។

11. អនុលោមតាមវិធានផ្ទៃក្នុង ៥៥(១០), ចែងពីបណ្តឹងឧទ្ធរណ៍ នៅក្នុងករណីជាក់លាក់ ដែលវិធាននេះចែងថា:

> នៅគ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រម សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធឲ្យបានឆាប់បំផុត តាមដែលអាចធ្វើទៅបាន ហើយនៅគ្រប់ករណីទាំងអស់ត្រូវចេញដីកានេះឲ្យបានមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ ដីកាបដិសេធនេះ ត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ភាគី។ ដីកាបដិសេធនេះត្រូវប់កផ្លូវបុ្តឹងឧទ្ធរណ៍[16]។

12. ដូចនេះ វិធាននេះផ្តល់មូលដ្ឋានសម្រាប់សំណើពីរប្រភេទ ដូចខាងក្រោម:
    - (i) ដីកាដែលចាំបាច់សម្រាប់ដំណើរការស៊ើបសួរ (សំណើទូទៅ) និង
    - (ii) កិច្ចស៊ើបសួរដែលចាំបាច់សម្រាប់ដំណើរការស៊ើបសួរ (សំណើសុំបំពេញកិច្ចស៊ើបសួរ)។

13. ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រមនឹងសំណើ អនុលោមទៅតាមប្រយោគចុងក្រោម សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធ ដែលបើកផ្លូវប្តឹងឧទ្ធរណ៍។ សំណើទាំងពីរប្រភេទនេះជាកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍។ ពុំមានការញែកឲ្យដាច់ពីគ្នារវាងដីកាបដិសេធលើសំណើទូទៅ និងដីកាបដិសេធលើសំណើសុំបំពេញកិច្ចស៊ើបសួរ។ អាស្រ័យហេតុនេះ វិធាន ៥៥(១០) ចែងពីសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធលើសំណើទូទៅ និងសំណើសុំបំពេញកិច្ចស៊ើបសួរ។

14. វិធាន ៧៤(៣)(ខ) កម្រិតសិទ្ធិរបស់ជនត្រូវចោទចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំបំពេញកិច្ចស៊ើបសួរ ដែលអនុញ្ញាតដោយវិធានផ្ទៃក្នុងទាំងនេះ។

---

[16] បញ្ជាក់បន្ថែម។

15. មេធាវីការពារក្ដីសូមស្នើថា ដើម្បីបញ្ចៀសនូវភាពមិនស៊ីចង្វាក់គ្នារវាងវិធានផ្ទៃក្នុងទាំងពីរនេះ ប្រសិនបើវិធានណាមួយត្រូវបានគេយល់ឃើញបែបហ្នឹង វិធាន ៥៥(១០) ត្រូវតែមានអធិកភាព។ ការបកស្រាយនេះ ត្រូវតែស្របតាមគោលការណ៍វិមតិសង្ស័យ (principle "*in dubio pro reo*") ដែលចែងថា នៅក្នុងករណីដែលច្បាប់លក្ខន្តិកៈ ឬវិធាន អាចត្រូវបកស្រាយយ៉ាងត្រឹមត្រូវតាមមធ្យោបាយពីរ ឬមធ្យោបាយច្រើនជាងនេះ ការបកស្រាយដែលផ្ដល់ផលប្រយោជន៍ដល់ជនត្រូវចោទ ត្រូវតែបានជ្រើសយក[17]។

16. អង្គបុរេជំនុំជម្រះមានយុត្តាធិការពិនិត្យលើបណ្ដឹងឧទ្ធរណ៍ នៅពេលណាដែលសិទ្ធិក្នុងការទទួលបានការជម្រះក្ដីយុត្តិធម៌របស់ជនត្រូវចោទ ត្រូវបានរំលោភ។

17. មានការគាំទ្រផ្នែកយុត្តិសាស្ត្រពីអង្គបុរេជំនុំជម្រះរបស់ អវតក នៅក្នុងសាលដីកាលើការបកប្រែឯកសារនៅក្នុងករណីខៀវ សំផន ទៅលើសំណើដែលថា ជនត្រូវចោទអាចប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ នៅក្នុងករណីមានការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌។ អង្គបុរេជំនុំសម្រេចថា អង្គបុរេជំនុំជម្រះនឹងពិនិត្យៈ

> [ អង្គបុរេជំនុំជម្រះ ] នឹងធ្វើការពិនិត្យថាតើវិធាន ២១ នៃវិធានផ្ទៃក្នុង តម្រូវឲ្យធ្វើការបកស្រាយសិទ្ធិរបស់ជនត្រូវចោទក្នុងប្ដឹងឧទ្ធរណ៍ ក្នុងន័យទូលាយដែរឬទេ ដើម្បីធានាថា ដំណើរការនីតិវិធីក្នុងពេលស៊ើបសួរ មានយុត្តិធម៌ និងបានគោរពគោលការណ៍ចំពោះមុខ ហើយបានរក្សានូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងអស់[18] ។

18. នៅក្នុងសាលដីកានោះ អង្គបុរេជំនុំជម្រះយល់ឃើញថា "សិទ្ធិរបស់ជនត្រូវចោទដែលត្រូវបានធានានៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង មិនត្រូវបានគេរំលោភឡើយ"[19] ។

> អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា វិធាន ២១ នៃវិធានផ្ទៃក្នុងមិនមានអនុភាពចាប់បង្ខំឲ្យធ្វើការបកប្រែវិធានផ្ទៃក្នុង ក្នុងវិធីមួយដែលនាំដល់ការប្រកាសទទួលយកបណ្ដឹងឧទ្ធរណ៍ចំពោះដីកាស្ដីពីការបកប្រែឡើយ[20] ។

---

[17] សូមមើល K. Khan & R. Dixon, *Archbold International Criminal Courts* (2005) ទំព័រ ១៦៥ ។

[18] ករណី ខៀវ សំផន, សាលដីកាលើបណ្ដឹងឧទ្ធរណ៍ទាក់ទងនឹងការបកប្រែឯកសារ ។

[19] ករណី ខៀវ សំផន, កថាខណ្ឌទី ៥០ នៃសាលដីកាលើបណ្ដឹងឧទ្ធរណ៍ទាក់ទងនឹងការបកប្រែឯកសារ ។

[20] ករណី ខៀវ សំផន, កថាខណ្ឌទី ៥០ នៃសាលដីកាលើបណ្ដឹងឧទ្ធរណ៍ទាក់ទងនឹងការបកប្រែឯកសារ ។

00374883



19. បន្ថែមពីលើនេះ បណ្ដឹងឧទ្ធរណ៍នេះគឺមានសារៈសំខាន់ជាសារវ័ន្តដើម្បីធានាថា ពុំមានរំលោភតទៅទៀតទៅលើសិទ្ធិក្នុងការទទួលបានការជម្រះក្ដីយុត្តិធម៌របស់ជនត្រូវចោទទេ ដែលការរំលោភនោះកើតឡើងតាមវិធីពីរយ៉ាងដូចខាងក្រោម:

(i) កិច្ចស៊ើបសួររបស់ កសចស និងដីកាដំណោះស្រាយនឹងសំអាងលើភស្តុតាងដែលប្រឡូកប្រឡាក់ និងដែលជាប់មកជាមួយនូវភាពមិនគួរឱ្យជឿជាក់បាន និង

(ii) មេធាវីការពារក្ដីអាចលើកបញ្ហានេះម្ដងទៀតនៅចំពោះមុខអង្គបុរេជំនុំជម្រះ ដែលបញ្ហានេះត្រូវតែបានដោះស្រាយនៅដំណាក់កាលស៊ើបសួរ។ ប្រសិនបើ កសចស សំអាងលើភស្តុតាងដែលជិតដាមដោយអំពើទារុណកម្ម នោះមេធាវីការពារក្ដីនឹងជំទាស់តវ៉ាទៅនឹងការប្រើប្រាស់របស់វា នៅដំណាក់កាលសវនាការ។ ប្រសិនបើអង្គបុរេជំនុំជម្រះបដិសេធដីការបស់ កសចស និងមិនទទួលយកភស្តុតាងដែលជិតដាមដោយអំពើទារុណកម្ម ដែលត្រូវបានសំអាងនៅក្នុងដំណើរនីតិវិធីរបស់ អវតក នោះដីកាដំណោះស្រាយ និងកិច្ចស៊ើបសួរនានាដែលជិតដាមដោយភស្តុតាងនៃអំពើទារុណកម្ម នឹងបង្គ្រោះយ៉ាងខ្លាំង។

20. វិធីសាស្ត្រនេះស្របគ្នានឹងវិធីសាស្ត្រដែលអនុវត្តដោយតុលាការអន្តរជាតិ និងតុលាអន្តរជាតុនីយកម្ម ដូចជា: ICTY, ICTR, ICC, តុលាការពិសេសសៀរ៉ាឡេអូន (SCSL) និងតុលាការពិសេសលីបង់ (STL) ដែលអនុញ្ញាតឱ្យមានបណ្ដឹងឧទ្ធរណ៍ នៅពេលមានបញ្ហាកើតឡើងដែលប៉ះពាល់យ៉ាងខ្លាំងដល់ដំណើរការជំម្រះក្ដីដោយយុត្តិធម៌ និងដោយឥតបង្អង់ ឬលទ្ធផលនៃការជំនុំជម្រះ និងនៅពេលដែលដំណោះស្រាយជាបន្ទាន់មួយដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ អាចជំរុញដំណើរការនីតិវិធីជាពុំខានឡើយ[21]។

21. ស្ថានភាពទាំងពីរនេះកើតនៅក្នុងករណីនេះ ដែលសិទ្ធិទទួលបានការជម្រះក្ដីដោយយុត្តិធម៌របស់ជនត្រូវចោទត្រូវបានគេរំលោភ ហើយសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះនឹងជំរុញដំណើរការនីតិវិធីជាពុំខានឡើយ។

---

[21] សូមមើលវិធាន ៧២(ខ)(ii) នៃវិធានស្ដីពីភស្តុតាង និងនីតិវិធីរបស់ ICTY, វិធាន ៧២(ខ)(ii) នៃវិធានស្ដីពីភស្តុតាង និងនីតិវិធីរបស់ ICTR, មាត្រា៨២(១)(ឃ) នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមបង្កើតតុលាការ ICC និងវិធាន ៧២(ច) នៃវិធានស្ដីពីនីតិវិធីរបស់តុលាការពិសេសសៀរ៉ាឡេអូន និងវិធាន 90(B)(ii) ស្ដីពីវិធាននីតិវិធី និងភស្តុតាងនៃតុលាការ STL។

00374884



22. ពិចារណាពីការទទួលស្គាល់របស់អង្គបុរេជំនុំជម្រះលើបញ្ហាការជម្រះក្តីដោយយុត្តិធម៌ ដែលបង្កើតបានជាមូលដ្ឋានដាច់ដោយឡែក សម្រាប់បណ្តឹងឧទ្ធរណ៍នៅក្នុងសេចក្តីសម្រេចស្តីពីការបកប្រែនៅក្នុងករណី ខៀវ សំផន និងការដែលថា តុលាការអន្តរជាតិ និងតុលាការអន្តរជាតុនីយកម្មដទៃទៀតអនុញ្ញាតឲ្យមានបណ្តឹងឧទ្ធរណ៍ ដោយមូលហេតុរំលោភការជម្រះក្តីដោយយុត្តិធម៌ និងការប្រាថ្នាចង់បានដំណើរនីតិវិធីឲ្យបានឆាប់រហ័ស មេធាវីការពារសូមអះអាងដោយគោរពថា អង្គបុរេជំនុំជម្រះមានយុត្តាធិការពិនិត្យលើបណ្តឹងឧទ្ធរណ៍នេះ ។

## IV សំណើសុំសវនាការផ្ទាល់មាត់

23. ពិចារណាពីភាពស្មុគស្មាញនៃបញ្ហានានានៅខាងក្រោម ព្រមទាំងសារៈសំខាន់ជាសារវ័ន្តនៅក្នុងបរិបទច្បាប់កម្ពុជា និងអន្តរជាតិ មេធាវីការពារសូមស្នើឲ្យមានសវនាការផ្ទាល់មាត់។ ហេតុដូច្នេះរាល់បញ្ហាដែលកើតឡើងទាក់ទងនឹងភាពស្មុគស្មាញនេះ ត្រូវដោះស្រាយដោយផ្ទាល់មាត់។

24. នៅក្នុង "សេចក្តីសម្រេចលើ"សំណើសុំឲ្យមានសវនាការផ្ទាល់មាត់" ទៅលើបណ្តឹងឧទ្ធរណ៍ អបជ ២៤ និងអបជ២៥[22] អង្គបុរេជំនុំជម្រះបានយល់ឃើញថា ជាវិធានទូទៅ អង្គបុរេជំនុំជម្រះមិនអាចដំណើរការសវានាការជាសាធារណៈបានទេ ទាក់ទងនឹងសំណើសុំបំពេញកិច្ចស៊ើបសួរនោះ ដោយសារតែចរិតធម្មជាតិនៃភាពសម្ងាត់របស់វា។ មេធាវីការពារសូមលើកឡើងថា ការយល់ឃើញនេះគឺមិនពាក់ព័ន្ធទៅនឹងបញ្ហាដែលបានលើកឡើងនៅក្នុងឧទ្ធរណ៍នេះទេ ដោយសារតែបណ្តឹងឧទ្ធរណ៍នេះត្រូវតែដោះស្រាយដោយតម្លាភាព ហើយក៏ពុំត្រូវការសំអាងទៅលើបញ្ហាដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរនោះដែរ។ អាស្រ័យហេតុនេះ មេធាវីការពារសូមអះអាងថា ចរិតធម្មជាតិនៃអំណះអំណាង គឺសមស្របសម្រាប់សវនាការជាធារណៈ ហើយអំណះអំណាងនេះនឹងជួយចៅក្រមក្នុងការដោះស្រាយរាល់បញ្ហា ដែលអាចកើតឡើង។

## V មូលដ្ឋានច្បាប់ពាក់ព័ន្ធ

### ៥.១ ច្បាប់កម្ពុជា

25. មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ចែងថា "ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធទេ។ វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"។

[22] អង្គសម្រេចរបស់អង្គបុរេជំនុំជម្រះ "លើសំណើសុំសវនាការផ្ទាល់មាត់" បណ្តឹងឧទ្ធរណ៍ PTC 24 និង 25 ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០០៩ ឯកសារ D164/4/3 ។

26. ស្រដៀងគ្នានេះដែរ មាត្រា២៤(៣)នៃច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់ ឆ្នាំ១៩៩២ ដែលនៅតែពាក់ព័ន្ធ ចែងថា "ពាក្យសារភាពដែលបានមកអំពីការបង្ខិតបង្ខំ តាមបែបណាក៏ដោយ ត្រូវទុកជាមោឃៈ"។ មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងកាន់តែច្បាស់ថា "ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយសារភាពដែលទទួលបានក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតំលៃជាភស្តុតាងបានឡើយ" ។ កាតព្វកិច្ចរបស់កម្ពុជាក្រោមច្បាប់អន្តរជាតិតម្រូវថា បទប្បញ្ញត្តិច្បាប់ទាំងនេះត្រូវតែបានបកស្រាយ ស្របតាមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម (**CAT**) ។

27. វិធាន ៨៧(១) នៃវិធានផ្ទៃក្នុងរបស់ អវតក ចែងថា "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក" ។ វិធាន ៨៧(២)(ឃ) ចែងថា អង្គជំនុំជម្រះអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា "ច្បាប់មិនអនុញ្ញាត" ។

28. វិធាន ៨៧(១) អាចត្រូវគេយល់ថា ជាវិធានទូទៅ (*lex generalis*) ។ បទបញ្ញត្តិនៃមាត្រា១៥ នៃអនុសញ្ញា CAT ចែងអំពីការច្រានចោលនូវភស្តុតាងដែលដិតដាមដោយការធ្វើទារុណកម្ម ហើយអាចត្រូវបានគេយល់ថា ជាវិធានទូទៅ (*lex generalis*) ដែលផ្តល់នូវស្ថានភាពមួយកាន់តែច្បាស់ជាងវិធានផ្ទៃក្នុង។ វិធានពិសេស (*lex specialis*) មានប្រៀបលើវិធានទូទៅ (*lex generalis*) ហើយវិធាន ១៥ នៃអនុសញ្ញា CAT ត្រូវតែបានពិចារណាដោយ អ.វ.ត.ក ។ មាត្រា ១៥ នៃអនុសញ្ញាប្រឆាំង CAT ក៏ស្របជាមួយវិធាន ៨៧(២)(ឃ) នៃវិធានផ្ទៃក្នុង ផងដែរ ។

29. សំខាន់ជាងនេះទៅទៀត វិធាននីតិវិធីនីរបស់ អ.វ.ត.ក មិនមានអធិកភាពលើកាតព្វកិច្ចរបស់កម្ពុជាក្រោមច្បាប់អន្តរជាតិនោះទេ។ អង្គជំនុំជម្រះវិសាមញ្ញ និងតុលាការរបស់កម្ពុជាដទៃ ត្រូវជាប់កាតព្វកិច្ចទៅនឹងសន្ធិសញ្ញាទាំងឡាយដែលចុះហត្ថលេខាដោយរដ្ឋាភិបាលកម្ពុជា។

30. ជាចុងក្រោយ វិធាន ២១ នៃវិធានផ្ទៃក្នុងចែងពីសិទ្ធិរបស់ជនត្រូវចោទ ទទួលបានការជម្រះក្តីដោយយុត្តិធម៌ និងដោយឥតបង្អង់ ស្របតាមមាត្រា ១៤ នៃអនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (**ICCPR**) ។

## ៥.២ ច្បាប់អន្តរជាតិ

31. មាត្រា ១៤(១) នៃ ICCPR ចែងថា "ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងវិស័យព្រហ្មទណ្ឌ ឬ លើសិទ្ធិ និងករណីកិច្ចក្នុងវិស័យរដ្ឋប្បវេណី។ ក្នុងផ្នែកទី២ នៃមាត្រា១៤ ចែងពីសច្ចធារណ៍នៃទោស ហើយមាត្រា ១៤(៣)(គ) ចែងពីសិទ្ធិទទួលបានការជម្រះក្តីដោយឥតបង្អង់។

32. មាត្រា ១៥ នៃអនុសញ្ញា CAT ចែងថា:[23]
"រដ្ឋភាគីត្រូវធានាថា ចម្លើយសារភាពដែលទទួលបានមកពីការធ្វើទារុណកម្ម មិនត្រូវពិចារណាថា ជាភស្តុតាងនៅក្នុងដំណើរការនីតិវិធីបានឡើយ លើកលែងតែកំណត់ហេតុផ្តល់ចម្លើយនោះ ត្រូវយកមកសំអាងជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទនៃអំពើទារុណកម្ម តែប៉ុណ្ណោះ"

33. មាត្រា២(២) នៃ នៃអនុសញ្ញា CAT បានចែងថាចរិតនៃបទបញ្ញត្តិនេះគឺមិនអាចដកហូតបានទេ។

34. មេធាវីការពារសូមស្នើថា អត្ថបទនៃបទប្បញ្ញត្តិនេះ គឺត្រូវបានកំណត់ដោយឯកឯង ដែលក្នុងនោះ ការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ត្រូវបានកម្រិតយ៉ាងតឹងរ៉ឹងបំផុតចំពោះតែការប្រើប្រាស់សម្រាប់"ប្រឆាំងទៅលើជនដែលត្រូវចោទប្រកាន់ពីការធ្វើទារុណកម្ម នូវភស្តុតាងដែលកើតចេញពីចម្លើយសារភាព"[24] ។

35. ខណៈជារដ្ឋហត្ថលេខីចំពោះអនុសញ្ញា CAT កម្ពុជាត្រូវជាប់កាតព្វកិច្ចទៅនឹងបទប្បញ្ញត្តិនៃមាត្រា ២៦ នៃអនុសញ្ញាក្រុងវីយែន ឆ្នាំ១៩៦៩ ស្តីពីច្បាប់សន្ធិសញ្ញា (**អនុសញ្ញាទីក្រុងវីយែន**) ហើយហេតុដូច្នេះ ចៅក្រមនៅ អ.វ.ត.ក រួមទាំងសហចៅក្រមស៊ើបអង្កេត ត្រូវតែគោរពបទប្បញ្ញត្តិនេះ។ លោកសាស្ត្រាចារ្យ Scharf បានទាញហេតុផលថា ចៅក្រមនៅ អ.វ.ត.ក មិនជាប់កាតព្វកិច្ចនឹងអនុសញ្ញានេះទេ ដោយហេតុថា អ.វ.ត.ក គឺជានិតិបុគ្គលដាច់ដោយឡែក ដែលមិនត្រូវចងភ្ជាប់ទៅនឹងកាតព្វកិច្ចច្បាប់អន្តរជាតិរបស់កម្ពុជានោះឡើយ។ ប៉ុន្តែគាត់ទទួលស្គាល់ថា កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា តម្រូវឱ្យ អ.វ.ត.ក "អនុវត្តយុត្តាធិការរបស់ខ្លួនស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ" ហើយគាត់ស្នាក់ស្ទើរក្នុងការធ្វើសន្និដ្ឋានថា "យ៉ាងហោច

[23] ប្រទេសកម្ពុជាទទួលស្គាល់អនុសញ្ញានេះ នៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ សូមមើល URL: http://www2.ohchr.org/english/bodies/ratification/9.htm.

[24] បញ្ជាក់បន្ថែម ។

ណាស់ តុលាការកម្ពុជាមិនចង់ឲ្យគេយល់ថា ខ្លួនកំពុងរំលោភលើអនុសញ្ញាទារុណកម្មយ៉ាងធំអាក្រក់ឡើយ ដែលនាំឲ្យអន្តរាយដល់និត្យានុកូលភាពរបស់ខ្លួន និងការគាំទ្រពីអន្តរជាតិ"នោះទេ[25]។ លោក Thienel បានទាញហេតុផលបន្តទៀតថា ក្រៅពីច្បាប់សន្ធិសញ្ញា វាអាចត្រូវបានគេអះអាងថា "កាតព្វកិច្ចក្រោមមាត្រា១៥នៃអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម បានសម្រេចជាឋានៈច្បាប់ទំនៀមទម្លាប់"[26]។

36. បទអត្ថាធិការប្បាយទូទៅលេខ ២០ ចំពោះមាត្រា ៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងសិទ្ធិនយោបាយ ("ICCPR") ដែលបញ្ចេញដោយការិយាល័យឧត្តមស្នងនៃការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស មានអត្ថន័យថា:
"វាមានសារៈសំខាន់ណាស់ក្នុងការមិនលើកទឹកចិត្តឲ្យរំលោភបំពានក្រោមមាត្រា ៧ ដែលចែងថា ច្បាប់ត្រូវតែហាមឃាត់ការទទួលយកនូវកំណត់ហេតុផ្តល់ចម្លើយ ឬចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្ម ឬ ការធ្វើប្រព្រឹត្តកម្មផ្សេងទៀតដែលច្បាប់ហាម"[27]។

37. នៅក្នុងរបាយការណ៍ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៣ គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម (ជាស្ថាប័នរបស់អង្គការសហប្រជាជាតិទទួលភារកិច្ចតាមដានអនុសញ្ញាCAT) បានផ្តល់អនុសាសដល់ប្រទេសកម្ពុជា[28]។ នៅក្នុងឯកសារនេះ គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្មដោយបានបញ្ជាក់ពីការព្រួយបារម្ភរបស់ខ្លួនអំពី"ការទទួលយកចម្លើយសារភាពនៅក្នុងដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌ និងការដែលនគរបាលនិងតុលាការពឹងផ្អែកលើចម្លើយសារភាពដើម្បី

---

[25] M.P. Scharf, "Tainted Provenance: ប្រសិនបើអាច តើនៅពេលណាដែលភស្តុតាងដែលបានមកដោយការធ្វើទារុណកម្មត្រូវបានទទួលយក? When, If Ever, Should Torture Evidence Be Admissible?", in: 65 Wash & Lee L. Rev. 129 (Winter 2008), (Annex 4) at 135-136.

[26] T. Thienel "ការទទួលយកភស្តុតាងដែលបានមកពីធ្វើទារុណកម្ម ក្រោមច្បាប់អន្តរជាតិ (The Admissibility of Evidence Obtained by Torture under International Law)០: ទនានុប្បវត្តិនៃច្បាប់អន្តរជាតិសហភាពអឺរ៉ុបលេខ ១៧ (ឆ្នាំ២០០៦) ៣៤៩, (ឧបសម្ព័ន្ធ ៧) នៅទំព័រ ៣៦៥ ។

[27] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស, បទអត្ថាធិប្បាយទូទៅលេខ ២០ ស្តីពីទារុណកម្ម, ការប្រព្រឹត្តឃោរឃៅឬការបន្ទាបបន្ថោកឬការដាក់ទណ្ឌកម្ម (មាត្រា៧)០:30/05/82 CCPR បទអត្ថាធិប្បាយទូទៅលេខ ២០ (បទអត្ថាធិប្បាយទូទៅ) URL address:
http://www.unhchr.ch/tbs/doc.nsf/0/6924291970754969c12563ed004c8ae5? Opendocument

[28] គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម, សេចក្តីសន្និដ្ឋាន និង អនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម: កម្ពុជា ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០០៣, ឯកសារលេខ CAT/C/CR/30/2 (សេចក្តីសន្និដ្ឋានទៅលើការសង្កេតការ/អនុសាសន៍), URL address: http://www.unhchr.ch/tbs/doc.nsf/(Symbol)/CAT.C.CR.30.2.En? Open Document.

00374888



ផ្តន្ទាទោស"[29]។ ជាពិសេស គណៈកម្មាធិការនេះបានផ្តល់ដំបូន្មានដល់កម្ពុជា "ឲ្យចាត់វិធានការដើម្បីធានាថា ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម មិនត្រូវលើកមកសំអាងនៅតុលាការឡើយ"[30] ។

38. អង្គការ Redress កាលពីឆ្នាំ ២០០៦ បានចេញផ្សាយនូវរបាយការណ៍មួយស្តីពីការអនុវត្តនៅថ្នាក់ជាតិនៃកាតព្វកិច្ចអន្តរជាតិ ទាក់ទងនឹងការឃាមឃាត់ការធ្វើទារុណកម្ម។ របាយការណ៍បានគូសបញ្ជាក់ពីអាយ័ត្រកម្មនៃមាត្រា ១៥ នៃអនុសញ្ញា CAT និងបានបង្ហាញពីទិដ្ឋភាពមួយចំនួនចំនួននៃអាយ័ត្រកម្មនោះ។ របាយការណ៍នេះដែលនៅពាក់ព័ន្ធ ថែងថា "អាយ័ត្រកម្មត្រូវតែគ្មានលក្ខខណ្ឌដោយគ្មានការលើកលែង ហើយមិនអនុញ្ញាតឲ្យចៅក្រម និងអ្នកធ្វើសេចក្តីសម្រេចដទៃទៀតប្រើអំណាចថា តើត្រូវទទួលយក ឬតើត្រូវថ្លឹងថ្លែងយ៉ាងដូចម្តេច ដើម្បីទទួលយកភស្តុតាងបែបនេះ"[31]

39. អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោឃៅដទៃទៀត ការប្រព្រឹត្តអមនុស្សធម៌ ឬបន្ទាបបន្ថោក ឬការដាក់ទណ្ឌ បានដាក់របាយការណ៍កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៦ ទៅមហាសន្និបាតរបស់អង្គការសហប្រជាជាតិ[32]។ នៅក្នុងរបាយការណ៍នេះ មានផ្នែកមួយនិយាយអំពី "គោលការណ៍មិនទទួលយកភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម" ដោយពិពណ៌នាលំអិតពីមាត្រា ១៥ នៃអនុសញ្ញា CAT ។ ជាបឋម របាយការណ៍នេះបានយោងទៅលើករណីរវាងប្រទេសអាឡឺម៉ង់តទល់ជាមួយ *Mounir el Motassadeq*[33] ដែលតុលាការកំពូល

[29] គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម, សេចក្តីសន្និដ្ឋាន និង អនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងទារុណកម្មៈ កម្ពុជា ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០០៣, ឯកសារលេខ CAT/C/CR/30/2 (សេចក្តីសន្និដ្ឋានទៅលើការសង្កេតការ/អនុសាសន៍), URL address: http://www.unhchr.ch/tbs/doc.nsf/(Symbol)/CAT.C.CR.30.2? Open Document, កថាខណ្ឌ 6 (h)

[30] គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម, សេចក្តីសន្និដ្ឋាន និង អនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងទារុណកម្មៈ កម្ពុជា ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០០៣, ឯកសារលេខ CAT/C/CR/30/2 (សេចក្តីសន្និដ្ឋានទៅលើការសង្កេតការ/អនុសាសន៍), URL address: http://www.unhchr.ch/tbs/doc.nsf/(Symbol)/CAT.C.CR.30.2? Open Document, កថាខណ្ឌ 7 (f)

[31] Redress Bringing the International Prohibition of Torture Home. ការអនុវត្តនៅថ្នាក់ជាតិ មគ្គុទ្ទេសសម្រាប់អនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងទារុណកម្ម និង ការប្រព្រឹត្តឃោឃៅដទៃទៀត, អមនុស្សធម៌ ឬ បន្ទាបបន្ថោក ឬ ការដាក់ទណ្ឌកម្ម ខែមករា ឆ្នាំ២០០៦, ទំព័រ ៦២ (ឧបសម្ព័ន្ធ ១) ។

[32] មហាសន្និបាតរបស់អង្គការសហប្រជាជាតិ, ទារុណកម្ម និង ការប្រព្រឹត្តឃោឃៅដទៃទៀត, អមនុស្សធម៌ ឬ បន្ទាបបន្ថោក ឬ ការដាក់ទណ្ឌកម្មឯកសារ UN Doc. No. A/61/259, ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៦ (ឧបសម្ព័ន្ធ២) ។

[33] *Beschluss IV – 1/04 des Hanseatischen Oberlandesgericht Hamburg,* Neue Juristische Wochenschrift 2005 Heft 32 of 14 June 2005 បានយោងនៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ, ទារុណកម្ម និង ការប្រព្រឹត្តឃោឃៅ

00374889



អាឡឺម៉ង់កាលពីថ្ងៃទី ៤ ខែមីនា ឆ្នាំ២០០៤ បានច្រានចោលសេចក្តីសម្រេចរបស់តុលាការជាន់ទាប ដែលសំអាងលើភស្តុតាងទទួលបានមកពីការធ្វើទារុណកម្ម។ រឿងក្តីនេះបានបញ្ជូនទៅតុលាការ Hamburg ដើម្បីជម្រះឡើងវិញ ដែលតុលាការនេះបានច្រានចោលភស្តុតាងដែលប្រឡូកប្រឡាក់ដោយអំពើទារុណកម្ម[34] ។

40. របាយការណ៍នេះក៏បានយោងបន្តទៅលើសេចក្តីសម្រេចចុះថ្ងៃទី៨ ខែ ធ្នូឆ្នាំ២០០៥ ក្នុងករណី *A និងអ្នកដទៃទៀត តទល់ជាមួយ SSHD (No.2)* នៃសភាជាន់ខ្ពស់របស់ប្រទេសអង់គ្លេស(House ofLords)[35]។ សភាជាន់ខ្ពស់សម្រេចជាឯកច្ឆ័ន្ទ នៅក្នុងការថ្កោលទោសរបស់ខ្លួនប្រឆាំនឹងការធ្វើទារុណកម្ម។ សភាជាន់ខ្ពស់ទទួលថាមាត្រា ១៥ នៃអនុសញ្ញា CAT បានតម្រូវឋានៈគោលការណ៍នៃវិធានដាច់ខាត (jus cogens) និងហាមឃាត់ការប្រើប្រាស់ភស្តុតាងនៅក្នុងដំណើរការនីតិវិធី ប្រសិនបើភស្តុតាងដែលលើកមកសំអាងនោះ ទទួលបានមកពីការធ្វើទារុណកម្ម។

41. មាត្រា ២៣ ថ្មី នៃច្បាប់បង្កើត អវតក ចែងថាៈ
"ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំមានចែងពីករណីពិសេសណាមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ប្រសិនបើមានបញ្ហាទាក់ទិនទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះ ជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ" ។

42. ការណែនាំត្រូវបានផ្តល់ដោយវិធាន ៩៥ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) និងប្រទេសរ៉ាវ៉ាន់ដា (ICTR) ដែលចែងថាៈ

---

ដទៃទៀត, អមនុស្សធម៌ ឬ បន្ទាបបន្ថោក ឬ ការដាក់ទណ្ឌកម្ម ឯកសារ UN Doc. No. A/61/259, ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៦ (ឧបសម្ព័ន្ធ២) កថាខណ្ឌ ៤៦។

[34] មហាសន្និបាតអង្គការសហប្រជាជាតិ, ទារុណកម្ម និង ការប្រព្រឹត្តឃោរឃៅដទៃទៀត, អមនុស្សធម៌ ឬ បន្ទាបបន្ថោក ឬ ការដាក់ទណ្ឌកម្មឯកសារ UN Doc. No. A/61/259, ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៦ (ឧបសម្ព័ន្ធ២) ទំព័រ ១១ ដល់ ១៤ ។

[35] មហាសន្និបាតអង្គការសហប្រជាជាតិ, ទារុណកម្ម និង ការប្រព្រឹត្តឃោរឃៅដទៃទៀត, អមនុស្សធម៌ ឬ បន្ទាបបន្ថោក ឬ ការដាក់ទណ្ឌកម្ម ឯកសារ UN Doc. No. A/61/259, ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៦ (ឧបសម្ព័ន្ធ២) ទំព័រ១៤ ដល់១៦ ។ សូមមើលការពិភាក្សានៃករណីនេះ, T. Thienel "អំពើទារុណកម្មរបស់បរទេស និង ភាពអាចទទួលយកបាននៃភស្តុតាង ។ សេចក្តីសម្រេចរបស់សភាជាន់ខ្ពស់ (House of Lords) នៅក្នុងករណី *A និង អ្នកដទៃទៀត តទល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ* (លេខ ២)" នៅក្នុងកាល្បវត្តិយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ៤ (២០០៦) ៤១០ (ឧបសម្ព័ន្ធ ៨) ។

"ភស្តុតាងនឹងមិនអាចយកជាការបានឡើយ ប្រសិនបើភស្តុតាងនោះបានមកតាមមធ្យោបាយទាំងឡាយណាដែលបង្កប់នូវវិមតិសង្ស័យជាដុំកំភួនលើភាពដែលអាចជឿទុកចិត្តបាននៃភស្តុតាង ឬការទទួលយកភស្តុតាងទំនងជាប្រឆាំងដល់ នឹង ទំនងជាបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់សុច្ចរិតភាពនៃដំណើរការនីតិវិធី" ។

43. តុលាការ ICTY បានបកស្រាយវិធាន ៩៥ យ៉ាងទូលំទូលាយ ហើយបានកត់សំគាល់ថា "ពុំមានមន្ទិលសង្ស័យនោះទេ ប្រសិនបើការសារភាពទទួលបានពីជនសង្ស័យដោយមិនស្ម័គ្រចិត្ត ប៉ុន្តែទទួលបានដោយការបង្ខិតបង្ខំ នឹងមិនអាចជាប់តេស្តនៃវិធាន៩៥ ឡើយ[36]។

44. មាត្រា ៦៩(៧) នៃច្បាប់លក្ខន្តិកៈបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ មានបទប្បញ្ញត្តិដូចគ្នា ប៉ុន្តែប្រើវាក្យសព្ទខុសគ្នាបន្តិច។

45. មេធាវីការពារមិនបានដឹងពីករណីណាមួយ ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិណាមួយក្នុងចំណោមតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត បានសម្រេចពីភាពយកជាបានការនៃភស្តុតាងដែលបានមកពីការធ្វើទារុណានោះឡើយ។ តុលាការជាតិ និងតុលាការអន្តរជាតិ ព្រមទាំងក្រុម អ្នកសិក្សាស្រាវជ្រាវនានាបានទទួលស្គាល់ថា ព័ត៌មានដែលបានមកពីការធ្វើទារុណកម្ម គឺជាភស្តុតាងដែលមិនអាចជឿទុកចិត្តបាន និងជាភស្តុតាងដែលជិតដាម ហើយជាគោលការណ៍ មិនអាចប្រើប្រាស់នៅក្នុងតុលាការព្រហ្មទណ្ឌបានឡើយ។ ម្យ៉ាងទៀត វិធាន៩៥ នៃវិធានស្តីពីភស្តុតាង និងនីតិវិធី និងមាត្រា ៦៩(៧) នៃច្បាប់លក្ខន្តិកៈក្រុងរ៉ូម គឺជាវិធានដាច់ខាត។ ជាផលវិបាក ប្រសិនបើព្រះរាជអាជ្ញាណាម្នាក់ស្វែងរកនូវការលើកហេតុផលចំពោះភស្តុតាងបែបនេះ នឹងប្រឈមជាមួយបន្ទុកមួយដែលមិនអាចដោះបានឡើយ ។

## VI មូលហេតុទី ១ នៃបណ្តឹងឧទ្ធរណ៍: ការរំលោភលើការជំនុំជម្រះក្តីដោយយុត្តិធម៌

46. ប្រទេសកម្ពុជាទទួលស្គាល់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មនៅឆ្នាំ ១៩៩២ ហេតុដូច្នេះកម្ពុជា ក៏ដូចជាអង្គជំនុំជម្រះវិសាមញ្ញដែរ ត្រូវជាប់កាតព្វកិច្ចចំពោះបទប្បញ្ញត្តិនៃអនុសញ្ញានេះ ។ ប្រទេសកម្ពុជាគឺជាភាគីរបស់ ICCPR ហើយមាត្រា ១៤ នៃកតិកាសញ្ញានេះធានាសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ ការធានាដែលបង្កើតជាគោលការណ៍ជាសារវ័ន្ត មានចែងនៅក្នុងវិធា ២១ នៃវិធានផ្ទៃក្នុងរបស់ អវតក។ ការប្រើប្រាស់ភស្តុតាងដែល

[36] *ករណីព្រះរាជអាជ្ញា តទល់ជាមួយ Delalic និងអ្នកដទៃទៀត* សេចក្តីសម្រេចលើពាក្យស្នើសុំរបស់ Zdravko Mucic ដើម្បីទាត់ចោលភស្តុតាង, រឿងក្តីលេខ IT-96-21-T, 2 September 1997 កថាខណ្ឌទី ៤១។

បានមកដោយការធ្វើទារុណកម្ម នឹងរំលោភលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដូចដែលបានការពារដោយ ICCPR និងច្បាប់បង្កើត អវតក។

47. ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ត្រូវបានគេទទួលស្គាល់ជាសកលថាមិនអាចជឿទុកចិត្តបាន។ ម្យ៉ាងវិញទៀត ការប្រើប្រាស់នូវភស្តុតាងបែបនេះថា ជាភស្តុតាងតម្រុយសម្រាប់ការស៊ើបអង្កេត នឹងបង្កការអន្តរាយដល់ដំណើរការនីតិវិធី។ ឧទាហរណ៍ បើសិនសាក្សីម្នាក់ ត្រូវបានដាក់តទល់ជាមួយចម្លើយសារភាព សាក្សីរូបនេះអាចទទួលរងនូវឥទ្ធិពលពីភស្តុតាង ដែលមិនអាចជឿទុកចិត្តបាន។ ជនត្រូវចោទពិតជាមិនអាចត្រួតពិនិត្យអំពីការប្រើប្រាស់ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្មបានទេ ដោយសារតែដំណើរការពុំមានតម្លាភាពគ្រប់គ្រាន់ ដើម្បីត្រួតពិនិត្យនីតិវិធីបែបនេះ។

48. ដូចមានបញ្ជាក់នៅក្នុងកថាខណ្ឌទី ២៣ នៃ ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម [ដាក់ការយោង] ទស្សនទាននៅខាងក្រោយមាត្រា ១៥ CAT ការច្រាន ចោលភស្តុតាង គឺមានពីរផ្នែកៈ ទី១ ព័ត៌មានដែលបានមកពីការធ្វើទារុណកម្ម គឺមិនអាចជឿទុកចិត្ត បាន និងទី២ ការហាមឃាត់ការប្រើប្រាស់ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម នឹងចូលរួមចំណែកក្នុងការទប់ស្កាត់ការអនុវត្តបែបនោះ[37]។

49. បើពិចារណាទៅលើអញ្ញត្រកម្មនៃមាត្រា ១៥ នៃអនុសញ្ញា CAT គណៈកម្មាធិការទទួលបន្ទុកសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ស្ថាប័នជំរុញការអនុវត្ត ICCPR ថ្លែងថា "ការដកហូតគោលការណ៍ជាសារវ័ន្តនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ រួមទាំងសច្ចធារណ៍នៃទោសផងដែរ ត្រូវបានហាមឃាត់នៅគ្រប់ពេលវេលាទាំងអស់"។

50. មេធាវីការពារក្តីសូមអះអាងថា ដីការបស់ កសចស រំលោភលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជំម្រះក្តីដោយយុត្តិធម៌ ហេតុដូច្នេះ ត្រូវបដិសេធដីកានេះ ដោយផ្អែកតាមមូលហេតុនេះ។

[37] គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម, សេចក្តីសន្និដ្ឋាន និង អនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងទារុណកម្មៈ កម្ពុជា ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០០៣, ឯកសារលេខ CAT/C/CR/30/2 (សេចក្តីសន្និដ្ឋានទៅលើការសង្កេតការ/អនុសាសន៍), URL address: http://www.unhchr.ch/tbs/doc.nsf/(Symbol)/CAT.C.CR.30.2? Open Document, កថាខណ្ឌទី ៤៥។

## VII មូលហេតុទី ២ នៃបណ្តឹងឧទ្ធរណ៍: មាត្រា ១៥ៈ អញ្ញត្រកម្មមិនត្រូវដាក់កម្រិតចំពោះការធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងឡើយ

51. កថាខណ្ឌទី ២១ នៃដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ថែងពីការបកស្រាយរបស់ កសចស លើអញ្ញត្រកម្មនៅក្នុងមាត្រា ១៥ នៃអនុសញ្ញា CAT ដោយបានកត់សំគាល់ថា ចម្លើយសារភាពនឹងមិនប្រើប្រាស់ប្រឆាំងនឹងជនរងគ្រោះនៃអំពើទារុណកម្មទេ ហេតុដូច្នេះ ការព្រួយបារម្ភទាក់ទងនឹងសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មិនអនុវត្តទេ។ មេធាវីការពារក្តីសូមអះអាងថា សនិទានភាពនៃមាត្រា១៥ នៃអនុសញ្ញា CAT មិនដាក់កម្រិតចំពោះបញ្ហានៃការធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ដោយជនរងគ្រោះនៃអំពើទារុណកម្មឡើយ។

52. ទាក់នឹងចំនុចនេះ Thobias Thienel ទាញហេតុផលថា តើការធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង គឺជាទិដ្ឋភាពមួយសម្រាប់វាយតំលៃលើអញ្ញត្រកម្មនៅក្នុងមាត្រា១៥នៃអនុសញ្ញា CAT ដែរឬយ៉ាងណា គឺមិនជាប់ព័ន្ធទេ ដោយហេតុថា "មនុស្សម្នាក់ប្រហែលជានឹងមិនធ្វើសក្ខីកម្មប្រឆាំងនឹងអ្នកដទៃដែលទទួលរងនូវអំពើទារុណកម្ម ក្រៅតែពីការធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងនោះទេ"[38]។ ជាថ្មីម្តងទៀត វាដោយសារតែភាពមិនអាចឲ្យជឿជាក់បាននៃខ្លឹមសាររបស់ចម្លើយសារភាព ដែលស្ថិតនៅជាបញ្ហា។ Thobias Thienel បានសន្និដ្ឋានថា "ដោយសារតែមាត្រា ១៥ នៃច្បាប់ព្រហ្មទណ្ឌអ៊ិនតាក់អនុវត្តចំពោះការបង្កើតភស្តុតាងប្រឆាំងនឹងជនម្នាក់ តាមរយៈចម្លើយសារភាពដោយបង្ខិតបង្ខំរបស់អ្នកផ្សេង ជាសេចក្តីសន្និដ្ឋានដូចគ្នានឹងមាត្រា ៦(១) នៃ ECHR [សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌] គឺត្រូវបានអនុវត្តបន្ត"[39]។

---

[38] T. Thienel "ការទទួលយកភស្តុតាងដែលបានមកពីធ្វើទារុណកម្ម ក្រោមច្បាប់អន្តរជាតិ (The Admissibility of Evidence Obtained by Torture under International Law)ៈ ទនានុប្បវត្តិនៃច្បាប់អន្តរជាតិសហភាពអឺរ៉ុបលេខ ១៧ (ឆ្នាំ២០០៦) ៣៤៩, (ឧបសម្ព័ន្ធ ៧) នៅទំព័រ ៣៥៨ ។

[39] T. Thienel "ការទទួលយកភស្តុតាងដែលបានមកពីធ្វើទារុណកម្ម ក្រោមច្បាប់អន្តរជាតិ (The Admissibility of Evidence Obtained by Torture under International Law)ៈ ទនានុប្បវត្តិនៃច្បាប់អន្តរជាតិសហភាពអឺរ៉ុបលេខ ១៧ (ឆ្នាំ២០០៦) ៣៤៩, (ឧបសម្ព័ន្ធ ៧) នៅទំព័រ ៣៥៩ ។ អក្សរក្នុងលេខយោងត្រូវបានដកចេញ។

00374893



53. គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្មខ្លួនឯងបានថ្លែងថា មាត្រា១៥ ក៏អនុវត្តចំពោះចម្លើយសារភាព ដែលមិនបានធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងផងដែរ ហើយថ្លែងបន្តទៀតថា ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ត្រូវតែបដិសេធចោលពីគ្រប់ដំណើរការនីតិវិធីទាំងអស់[40]។

54. មេធាវីការពារក្តីសូមអះអាងថា កសចស បានបកស្រាយមិនត្រឹមត្រូវចំពោះការអនុវត្តមាត្រា ១៥ នៃអនុសញ្ញា CAT ចំពោះស្ថានភាពនៃការកើតឡើងនៃបញ្ហាការធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ហេតុដូច្នេះ ត្រូវបដិសេធដីកានេះ។

## VIII មូលហេតុទី ៣ នៃបណ្តឹងឧទ្ធរណ៍ : ការបកស្រាយប្រឆាំងនឹង "ន័យធម្មតា"

### ៨.១ ស្មារតីរបស់ច្បាប់ តទល់នឹង តួអក្សររបស់ច្បាប់

55. នៅក្នុងកថាខណ្ឌទី ២៣ នៃដីកា កសចស សំអាងនូវអ្វីដែលខ្លួនហៅថា "ស្មារតីរបស់ច្បាប់" និងបានលើកឡើងថា មិនត្រូវផ្តល់សារៈសំខាន់លើតួរអក្សររបស់ច្បាប់លើសលុបជាងស្មារតីរបស់ច្បាប់នោះទេ។ កសចស មិនបានផ្តល់និយមន័យ"ស្មារតីរបស់ច្បាប់"នេះទេ ហើយថាតើនៅពេលណា និងដោយរបៀបណា ហើយអ្វីដែលសំខាន់បំផុតនោះគឺថា ហេតុអ្វីបានជាស្មារតីរបស់ច្បាប់ខុសពីតួរអក្សររបស់ច្បាប់។ ដោយហេតុថា ប្រយោគបន្ទាប់នៅក្នុងកថាខណ្ឌទី២៣ ដែលដកស្រង់ចេញពីអនុសញ្ញាវ៉ៀនស្តីពីច្បាប់សន្ធិសញ្ញា កសចស ប្រហែលជាកំពុងស្វែងរកការប្រៀបធៀប "ស្មារតីរបស់ច្បាប់" ទៅនឹង"គោលបំណង"របស់អនុសញ្ញា។ គោលបំណង របស់អនុសញ្ញានេះគឺមានន័យច្បាស់លាស់ ហើយត្រូវបានឯកភាពដោយរដ្ឋជាភាគី និងជាពិសេស គឺ កសចស:

ជាបឋម ចម្លើយសារភាព ឬ ព័ត៌មានដទៃទៀត ដែលទទួលបានពីការធ្វើទារុណកម្ម គឺមិនមានតំលៃគ្រប់គ្រាន់ ដើម្បីយកមកប្រើប្រាស់នៅក្នុងនីតិវិធីតុលាការនោះទេ។ ទីពីរ ការហាមឃាត់មិនឲ្យប្រើប្រាស់ភស្តុតាងបែបនេះនៅក្នុងដំណើរនីតិវិធីតុលាការ ជួយទប់ស្កាត់ក្នុងការប្រើប្រាស់ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ដូច្នេះ វាគឺជាកម្លាំងដ៏ធំមួយដែលចូលរួមទប់ស្កាត់ការប្រព្រឹត្តអំពើនេះ[41]។

---

[40] សូមមើលកថាខណ្ឌទី ៩៥ នៃឯកសារ A/54/44 ដែលគណៈកម្មាធិការប្រឆាំងនឹងទារុណកម្មថ្លែងថា អនុលោមតាមច្បាប់អន្តរជាតិ "ចៅក្រម មិនត្រូវលើកយកមកពិចារណានូវភស្តុតាង និង ចម្លើយសារភាពដែលជិតដាមដោយអំពើទារុណកម្ម ដើម្បីធ្វើសេចក្តីសម្រេចលើរឿងក្តីនោះទេ"។

[41] មហាសន្និបាតអង្គការសហប្រជាជាតិ, ទារុណកម្ម និង ការប្រព្រឹត្តឃោរឃៅដទៃទៀត, អមនុស្សធម៌ ឬ បន្ទាបបន្ថោក ឬ ការដាក់ទណ្ឌកម្មឯកសារ UN Doc. No. A/61/259, ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០៦ កថាខណ្ឌទី ៤៥ ។ នៅក្នុងដីកាសម្រេច

00374894



56. ទោះបីជាកង្វះខាតនូវការវិភាគក៏ដោយ ក៏សេចក្តីសម្រេចរបស់ កសចស គឺថាន័យធម្មតារបស់មាត្រា ១៥ មិនស្របជាមួយគោលបំណងរបស់អនុសញ្ញានេះទេ ហេតុដូច្នេះ វាជំនួសមកវិញនូវការបកស្រាយផ្សេងរបស់ខ្លួន។

57. ការពន្យល់របស់ កសចស ផ្តល់នូវការបកស្រាយផ្សេងរបស់ខ្លួនដែលថា ការបកស្រាយនេះមិនផ្ទុយនឹងគោលបំណងរបស់អនុសញ្ញានេះទេ។ វិធីសាស្ត្រនៃការបកស្រាយសន្ធិសញ្ញានេះ គឺជាការបកស្រាយដោយភាន់ច្រឡំ ហើយមិនអនុញ្ញាតដោយច្បាប់អន្តរជាតិនោះទេ។ ប្រសិនបើជាការពិតនោះន័យធម្មតារបស់មាត្រា ១៥ ផ្ទុយទៅនឹងគោលបំណងរបស់អនុសញ្ញា CAT ហើយគេអាចទាញហេតុផលថា ន័យធម្មតារបស់ប្បញ្ញត្តិច្បាប់អាចផ្លាស់ប្តូរបាន ដើម្បីសម្រេចនូវគោលបំណងរបស់ច្បាប់។

58. ប៉ុន្តែ វាមិនមែនជាដំណោះស្រាយនៅទីនេះទេ។ នៅក្នុងការបកស្រាយ មាត្រា១៥ នៃអនុសញ្ញា CAT មានន័យច្បាស់លាស់ ហើយន័យធម្មតាមិនផ្ទុយទៅនឹងគោលបំណងរបស់អនុសញ្ញានេះទេ។ ដូច្នេះ កសចស បានខកខានក្នុងការគិតគូរឲ្យបានត្រឹមត្រូវដល់ពាក្យពិជន៍របស់ប្បញ្ញត្តិច្បាប់ ហើយបានភាន់ច្រឡំនៅក្នុងការបកស្រាយរបស់ខ្លួន[42]។

59. តុលាការយុត្តិធម៌អន្តរជាតិសម្រេចថា:

ប្រសិនបើពាក្យពេជន៍ពាក់ព័ន្ធនៅក្នុងន័យធម្មជាតិនិងធម្មតា មានន័យអត្ថន័យនៅក្នុងបរិបទរបស់ពួកគេ នោះគឺជាការបញ្ចប់នៃបញ្ហា។ម្យ៉ាងវិញទៀត ពាក្យពេជន៍នៅក្នុងន័យធម្មជាតិនិងន័យធម្មតា មានន័យមិនច្បាស់ ឬនាំឲ្យមានលទ្ធផលមិនសមហេតុផល ហេតុដូច្នេះ តុលាការត្រូវតែស្វែងរកការអះអាងចំពោះអត្ថន័យពិតប្រាកដដែលប្រើដោយភាគីតាមរយៈវិធីសាស្ត្រនៃការបកស្រាយផ្សេងៗ[43]។

---

របស់ខ្លួន កសចស ផ្លាស់ប្តូរផ្នែករបស់គោលបំណង និងទិសដៅរបស់អនុសញ្ញា ហេតុដូច្នេះ វាមានន័យថា ផ្នែកទីពរមានសារៈសំខាន់ជាងផ្នែកទីមួយ។

[42] សូមមើលដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម (SMD), ឯកសារ D164/2 កថាខណ្ឌទី ៦ ដែល កសចស ថ្លែងថា "កិច្ចស៊ើបសួរអាចបញ្ចប់ នៅពេលដែលសហចៅក្រមស៊ើបអង្កេតសំដែងការជឿជាក់ថា មានភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកទៅលើជនត្រូវចោទ"។ ដីកានេះក៏ត្រូវបានប្តឹងជំទាស់ដោយមេធាវីការពារក្តីដែរ។

[43] មតិយោបល់របស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ ) ទាក់ទងនឹងសមត្ថភាពនៃមហាសន្និបាតសម្រាប់ការបញ្ចូលរដ្ឋមួយទៅក្នុងអង្គការសហប្រជាជាតិ, របាយការណ៍របស់ ICJ (១៩៥០) ទំព័រ ៨ ដែលត្រូវបានយោងនៅក្នុងសាលដីការឿងក្តី

60. ម្យ៉ាងទៀត តុលាការយុត្តិធម៌អន្តរជាតិបានគូសបញ្ជាក់ថា "ការបកស្រាយត្រូវតែសំអាងលើអត្ថបទរបស់ច្បាប់"[44]។ អ្នកធ្វើអត្ថាធិប្បាយម្នាក់បាននិយាយថា "នៅពេលបទប្បញ្ញត្តិមានន័យច្បាស់ សេចក្តីត្រូវការរបស់វាក៏តិចតួច ហើយការបំណងប្រាថ្នារបស់តុលាការក៏មានតិចតួចដែរ ដើម្បីណែនាំនូវវិធានច្បាប់មិនចាំបាច់"[45]។

61. នៅក្នុងការពន្យល់ពីន័យនៃមាត្រា ១៥ របស់អនុសញ្ញា CAT លោកសាស្ត្រាចារ្យ Pattenden ពន្យល់ថា បទប្បញ្ញត្តិនេះត្រូវតែបានបកស្រាយយ៉ាងតឹងរឹងបំផុត ស្របតាមន័យធម្មតារបស់វា ដោយមិនគិតពីវិធីសាស្ត្រនៃការបកស្រាយ ដែលត្រូវបានប្រើឡើយ: អ្នកស្ត្រីសាស្ត្រាចារ្យបានកត់សំគាល់ដូចខាងក្រោម:

> មិនថាជាការស្រាយតាមន័យត្រង់ ឬការបកស្រាយបែបទេវវិទ្យានោះទេ មាត្រា ១៥ ដាក់កាតព្វកិច្ចដល់រដ្ឋជាភាគី ដើម្បីធានាថា ចម្លើយសារភាពដែលទទួលបានពីការធ្វើទារុណកម្ម ត្រូវតែប្រើប្រាស់ក្នុងសវនាការដើម្បីប្រឆាំងទៅលើអ្នកប្រព្រឹត្តអំពើទារុណកម្ម ហើយចម្លើយសារភាពនេះ ត្រូវបានប្រើប្រាស់តែដើម្បីបង្ហាញថា ចម្លើយសារភាពនេះត្រូវបានបង្កើត សម្រាប់គោលបំណងមិនមែនចចាមអារាមតែប៉ុណ្ណោះ[46]។

62. មេធាវីការពារក្តីសូមស្នើថា ជម្រើសនៃការបកស្រាយមួយ ដែលបំពេញចិត្ត កសចស បង្កើតបានជាយុត្តិធម៌ដោយអន្លើរ (judicial cherry-picking) និងមិនមែនជាការបកស្រាយត្រឹមត្រូវ ក្រោមនីតិសាធារណ:អន្តរជាតិនោះទេ[47]។ ន័យធម្មតារបស់អនុសញ្ញា CAT គឺច្បាស់លាស់ និងគ្មានន័យពីរឡើយ ហើយស្របតាមគោលបំណងរបស់អនុសញ្ញានេះទៀតផង និងពុំត្រូវមានការបកស្រាយផ្សេងនៃមាត្រា ១៥ នៃអនុសញ្ញា CAT ដោយ កសចស ឡើយ។

---

*ព្រះរាជអាជ្ញា តទល់ជាមួយ Akayesu* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល សំណុំរឿងលេខ: ICTR-96-4-A ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០១, ការថ្លែងយោលបល់ដោយចៅក្រម Judge Nieto-Navia, កថាខណ្ឌទី ៥។

[44] តុលាការយុត្តិធម៌អន្តរជាតិ, ករណី Libya / Chad របាយការណ៍របស់ ICJ (១៩៩៤) ទំព័រ ២, ២២ សំអាងនៅក្នុង *Public International Law* (2003) ទំព័រ ៣០៣។

[45] D. French "ការបកស្រាយច្បាប់សន្ធិសញ្ញា និង ការដាក់បញ្ចូលវិធានច្បាប់មិនចាំបាច់" in: International & Comparative Law Quarterly 281 (2006) ទំព័រ ៣០៣។

[46] R. Pattenden "ភាពអាចយកបាននៃភស្តុតាងដែលបានមកដោយការធ្វើទារុណកម្មទៅលើតតីយជន" in: *The International Journal of Evidence & Proof* (2006) ទំព័រ ៦។

[47] D. French "ការបកស្រាយច្បាប់សន្ធិសញ្ញា និង ការដាក់បញ្ចូលវិធានច្បាប់មិនចាំបាច់" in: International & Comparative Law Quarterly 281 (2006) ទំព័រ ៣០៦។

63. កសចស មានកំហុសនៅក្នុងការបកស្រាយរបស់ខ្លួននៃមាត្រា ១៥ ដែលផ្ទុយទៅនឹងការបកស្រាយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិហើយបានពឹងផ្អែកលើវិធីសាស្ត្រដែលមិនស្របជាមួយច្បាប់អន្តរជាតិ។ ជាផលវិបាក ត្រូវច្រានចោលការបកស្រាយផ្សេងៗរបស់ កសចស ហើយត្រូវបដិសេធដីកានេះ។

## ៨.២ ម្ចាស់ចម្លើយសារភាព គឺមិនពាក់ព័ន្ធ

64. ក្នុងការបកស្រាយ អញ្ញត្រកម្មដែលមានកម្រិតមានចែងនៅក្នុងមាត្រា ១៥ នៃអនុសញ្ញា CAT កសចស បញ្ជាក់នៅក្នុងកថាខណ្ឌទី ២១ នៃដីកាសម្រេចថា "វាប្រាកដហើយថា អញ្ញត្រកម្មនេះមិនអនុញ្ញាតឱ្យមានការប្រើប្រាស់នូវចម្លើយសារភាពដែលទទួលបានដោយអំពើទារុណកម្ម ដើម្បីប្រឆាំងនឹងជនរងគ្រោះនៃអំពើទារុណកម្ម ឬដើម្បីប្រឆាំងនឹងជនណាម្នាក់ ដែលត្រូវបានចោទប្រកាន់ដោយជនរងគ្រោះនៃអំពើទារុណកម្មនោះទេ"។ តាមពិតទៅ អញ្ញត្រកម្មដែលមានចែងនៅក្នុងមាត្រា ១៥ នៃអនុសញ្ញា CAT គឺពាក់ព័ន្ធតែទៅនឹងការប្រើប្រាស់ចម្លើយសារភាពដែលទទួលបានដោយការធ្វើទារុណកម្មនោះ អាចត្រូវបានដាក់ទៅក្នុងដំណើរការនីតិវិធី មានន័យថាប្រឆាំងនឹងអ្នកប្រព្រឹត្តអំពើទារុណកម្ម ដែលជាភស្តុតាងបញ្ជាក់ថា ចម្លើយសារភាពនោះត្រូវបានធ្វើឡើងតែប៉ុណ្ណោះ។

65. គណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្មបានលើកឡើងថា ភស្តុតាងដែលជិតដាមដោយអំពើទារុណកម្ម ត្រូវតែដកចេញពីដំណើរការនីតិវិធីព្រហ្មទណ្ឌ ទោះបីជាភស្តុតាងដែលទទួលបាននោះធ្វើឡើងដោយចុងចោទ សហចុងចោទ ឬតតីយជនណាម្នាក់ក៏ដោយ[48]។ នៅក្នុងរឿងក្តីរបស់ *A និងអ្នកដទៃទៀត ប្រឆាំងនឹង* ***SSHD*** (លេខ ២) សភាជាន់ខ្ពស់បានលើកឡើងថា ការទទួលយកការច្រានចោល គឺទូលំទូលាយណាស់។ ព្រឹទ្ធបុរស Bingham លើកឡើងថា "លក្ខណៈវិនិច្ឆ័យ

---

[48] CAT/C/SR.111, កថាខណ្ឌទី ៤៤ ដែលអាចរកតែក្នុងភាសាអេស្បាញ តែបានសំអាងនៅក្នុង R. Pattenden, "ការទទួលយកភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម ដោយតតីយជន" នៅក្នុងព្រឹត្តិប័ត្រអន្តរជាតិស្តីពីភស្តុតាង & សក្ខីកម្ម (២០០៦) ទំព័រទី ៧ 'Admissibility of Evidence Obtained by Torture of a Third Party', in: *The International Journal of Evidence & Proof* (2006)។

បន្ថែមធ្វើឱ្យមានការយល់ច្បាស់លាស់ ចំពោះលក្ខណៈគ្របដណ្តប់ទូទៅនៃវិធានច្រានចោលនេះ "លក្ខខណ្ឌបន្ថែមធ្វើឱ្យកាន់តែច្បាស់ពីចរិតលក្ខណៈរបស់វិធានច្រានចោល"[49]។

66. ការប្រើពាក្យពេចន៍នៃមាត្រា ១៥ គឺមានន័យច្បាស់លាស់ និងមិនស្រពិចស្រពិលនោះឡើយ។ ម្ចាស់ចម្លើយសារភាពដែលទទួលបានដោយអំពើទារុណកម្ម គឺមិនពាក់ព័ន្ធនោះទេ ហើយដូចគ្នានេះដែរ ចម្លើយសារភាពនេះក៏មិនពាក់ព័ន្ធទៅនឹងអ្នកដែលត្រូវបានគេចោទប្រកាន់ដោយសារតែចម្លើយសារភាពនោះដែរ។ ការបកស្រាយដែល កសចស បានសំអាងគឺមិនស្របតាមវិធីនានានៃការបកស្រាយសន្ធិសញ្ញា ដែលត្រូវបានអនុញ្ញាតដោយច្បាប់អន្តរជាតិ ដូចបានពន្យល់នៅក្នុងកថាខណ្ឌទី [xxx] ខាងលើស្រាប់។

## IX. មូលហេតុទី ៤ នៃបណ្តឹងឧទ្ធរណ៍: អញ្ញត្រកម្មនៃមាត្រា ១៥ ត្រូវតែអនុវត្ត

67. កសចស លើកឡើងថា "មិនមានមូលដ្ឋានកម្រិតចំពោះភាសានៃអញ្ញត្រកម្មទៅលើចារីផ្ទាល់តែឯងនោះទេ"[50]។ កសចស បន្តលើកឡើងថា ចម្លើយសារភាពអាចត្រូវបានប្រើប្រាស់ប្រឆាំងនឹងជនទាំងឡាយណា ដែលត្រូវបានចោទប្រកាន់ពីអំពើទារុណកម្ម បើទោះបីជាតាមរយៈទម្រង់នៃការទទួលខុសត្រូវដោយផ្ទាល់ ឬដោយប្រយោលក៏ដោយ។ បន្ទាប់មក កថាខណ្ឌ ២២ មិនបានបញ្ជាក់ថា ចម្លើយសារភាពដែលទទួលបានដោយការធ្វើទារុណកម្ម ត្រូវយកមកប្រើប្រាស់ប្រឆាំង*ចំពោះតែ*ជនដែលត្រូវបានចោទប្រកាន់ពីការធ្វើទារុណកម្ម ដើម្បីបង្ហាញថាចម្លើយសារភាពត្រូវបានធ្វើឡើងដោយការធ្វើទារុណកម្មនោះទេ។

68. កសចស លើកឡើងនូវការយល់ឃើញរបស់ខ្លួនក្នុងលក្ខណៈមួយដែលបញ្ជាក់ថា ចម្លើយសារភាពអាចយកមកប្រើប្រាស់ប្រឆាំងនឹងជនណាម្នាក់ ដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម

---

[49] *A និងអ្នកដទៃទៀត តទល់នឹង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ* (លេខ ២) [២០០៥] UKHL 71, [2005] 3 WLR 1249, URL address: www.parliament.the-stationery-office.co.uk/pa/ld200506/ldjudgmt/jd051208/aand. កថាខណ្ឌទី ៣៥។ សូមមើល ការពិភាក្សាពីការប្រើប្រាស់ភស្តុតាងភស្តុតាង ដែលជិតដាមដោយអំពើទារុណកម្ម នៅក្នុងបណ្តាតុលាការរបស់រដ្ឋដែលរដ្ឋនោះផ្ទាល់ខ្លួនមិនបានពាក់ព័ន្ធនៅក្នុងអំពើទារុណកម្មទេ។ T. Thienel "ការទទួលយកភស្តុតាងដែលជិតដាមដោយអំពើទារុណកម្មនៅក្រោមច្បាប់អន្តរជាតិ" នៅក្នុងព្រឹត្តិប័ត្រអឺរ៉ុបស្តីពីច្បាប់អន្តរជាតិ ១៧ (២០០៦) ៣៤៩ ទំព័រ។

[50] កថាខណ្ឌទី ២២ នៃដីកាសម្រេច ។

00374898



ទោះបីជាដោយផ្ទាល់ ឬដោយប្រយោលក្តី ហើយក៏ជាប់ទាក់ទងទៅនឹងបទចោទ ដែលជនត្រូវចោទកំពុងប្រឈមមុខ។ កថាខណ្ឌទី ២៨ នៃដីកាសម្រេចបង្ហាញថា កសចស បានបង្កើតនូវការបកស្រាយដ៏ទូលំទូលាយនេះ។

69. ភាសាតាមន័យចង្អៀតនៃមាត្រាទី ១៥ ហាមឃាត់ចំពោះការប្រប្រាស់ភស្តុតាងដែលដិតដាមដោយអំពើទារុណកម្ម នៅខាងក្រៅវិសាលភាពនៃមាត្រា ១៥ និងកំណត់ថាការប្រើប្រាស់ភស្តុតាងដែលដិតដាមដោយអំពើទារុណកម្ម គឺផ្ទុយនឹងច្បាប់។ ហេតុដូច្នេះ ដីកាសម្រេចនេះគួរត្រូវបានច្រានចោលដោយសំអាងទៅលើមូលហេតុនេះ ហើយការបកស្រាយដែលត្រឹមត្រូវគួរត្រូវបានយកមកអនុវត្ត។

## X. មូលហេតុទី ៥ នៃបណ្តឹងឧទ្ធរណ៍: ការហាមឃាត់ដាច់ខាតចំពោះការប្រើប្រាស់ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម

70. ដីកាសម្រេចបានបញ្ជាក់នៅក្នុងកថាខណ្ឌទី ២៥ ថា: ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម អាចយកមកប្រើប្រាស់នៅខាងក្រៅអញ្ញត្រកម្មនៃមាត្រា ១៥ ដែលបញ្ហានៃភាពគួរឱ្យជឿជាក់បានមិនកើតឡើងនោះទេ។ ក្រៅពីការដែលមេធាវីការពារក្តីជំទាស់តវ៉ាថា បញ្ហានៃភាពគួរឱ្យជឿជាក់បានគឺមិនមែនជាបញ្ហាសម្រាប់ប្រភេទទាំងពីរ ដែល កសចស លើកឡើងនៅក្នុងកថាខណ្ឌទី ២៧ និង២៨ មេធាវីការពារក្តីសូមលើកឡើងថា ការអនុវត្តមាត្រា ១៥ នៃអនុសញ្ញាអនុសញ្ញា CAT គឺមិនមែនគ្រាន់តែជាប់ពាក់ព័ន្ធទៅនឹងភាពអាចឱ្យជឿជាក់បាននៃភស្តុតាងប៉ុណ្ណោះ ហើយ កសចស បានភាន់ច្រឡំនៅក្នុងការបកស្រាយរបស់ខ្លួនជាថ្មីម្តងទៀត។

71. ដូចដែលបានបញ្ជាក់ដោយព្រឹទ្ធបុរសឈ្មោះ Hope នៅក្នុងករណី *A និងអ្នកផ្សេងទៀត តទល់នឹង SSHD* (លេខ ២)៖

> ការប្រើប្រាស់ភស្តុតាងបែបនេះត្រូវបានច្រានចោល មិនមែនដោយសារតែមូលហេតុនៃភាពមិនគួរឱ្យជឿជាក់បាននោះទេ ប្រសិនបើភាពមិនគួរឱ្យជឿជាក់បាននេះ គឺជាការជំទាស់តែមួយគត់ចំពោះការប្រើប្រាស់ភស្តុតាងបែបនេះ នោះវាគួរសំអាងទៅលើទម្ងន់នៃភស្តុតាងនេះ មិនមែនភាពគួរឱ្យទទួលយកបានរបស់ភស្តុតាងនេះទេ ផ្ទុយទៅវិញ គឺដោយសារតែមូលហេតុនៃភាពសាហាវយង់ឃ្នង អនីត្យានុកូលភាព និងភាពអមនុស្សធម៌របស់ភស្តុតាងបែបនោះទៅវិញទេ។ ច្បាប់នឹង

មិនផ្តល់ការគាំទ្រដល់ការប្រើប្រាស់អំពើទារុណកម្ម ដើម្បីគោលបំណងណាមួយនោះឡើយ[51]។ ច្បាប់ពុំមានផ្តល់ចំណុចណាក្នុងការការពារសេរីភាព និងលទ្ធិប្រជាធិបតេយ្យទេ ដែលអត្ថិភាពរបស់វាអាស្រ័យលើការបដិសេធនៃការប្រើប្រាស់វិធីសាស្ត្របែបនេះ ។

72. លើសពីនេះទៅទៀត រឿងក្តីដែលបានលើកឡើងបញ្ជាក់ថា ការទទួលយកភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្មអាចធ្វើឲ្យតក់ស្លុតដល់មនសិការយុត្តិធម៌ អាចរំលោភបំពាន ឬបន្ទាបបន្ថោកដល់ដំណើរការនីតិវិធី និងអាចធ្វើឲ្យរដ្ឋពាក់ព័ន្ធនៅក្នុងភាពកខ្វក់ខាងសីលធម៌ ហើយអាចខកខានមិនបានការពារដល់សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទទៀតផង[52]។ ក្នុងការផ្តល់គំនិតនាំមុខព្រឹទ្ធបុរសផ្សេងទៀត ព្រឹទ្ធបុរស Bingham បានបន្ថែមទៀតថា បន្ថែមទៅលើភាពមិនគួរឲ្យជឿជាក់បាននៃភស្តុតាងបានមកដោយការធ្វើទារុណកម្ម និងសេចក្តីត្រូវការដើម្បីរារាំងចំពោះការប្រើប្រាស់ភស្តុតាងបែបនោះ នោះមូលហេតុសម្រាប់វិធានដោះបន្ទុក ក៏ដើម្បីការពារដល់សុច្ចរិតភាពនៃដំណើរការនីតិវិធី ដោយអនុលោមតាមមាត្រាទី ៦៩(៧) នៃលក្ខន្តិកៈទីក្រុងរ៉ូមដែលចែងថា៖

> ភស្តុតាងដែលទទួលបានដោយមធ្យោបាយណាមួយ ដែលរំលោភទៅលើលក្ខន្តិកៈនេះ ឬសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ មិនត្រូវទទួលយកឡើយ ប្រសិនបើ៖ [...] (ខ) ការទទួលយកភស្តុតាងបែបនោះអាចប្រឆាំងចំពោះ ឬអាចធ្វើឲ្យខូចខាតធ្ងន់ធ្ងរដល់សុច្ចរិតភាពនៃដំណើរការនីតិវិធី។

73. មេធាវីការពារក្តីសូមលើកឡើងថា កសចស បានភ័ន្តច្រឡំនៅក្នុងការលើកឡើងថា ភាពគួរឲ្យជឿជាក់បាន គឺមានតែកត្តានៅខាងក្រៅមូលហេតុនៃមាត្រា ១៥ នៃអនុសញ្ញាអនុសញ្ញា CAT និងខកខានមិនបានពិចារណាពីច្បាប់ និងយុត្តិសាស្ត្រអន្តរជាតិ ដែលបញ្ជាក់យ៉ាងច្បាស់ ចំពោះមូលហេតុក្នុងការហាមឃាត់ការប្រើប្រាស់ភស្តុតាង ដែលដិតដាមដោយអំពើទារុណកម្ម។ ហេតុដូច្នេះ ដីកាសម្រេចនេះត្រូវតែបានច្រានចោល ដោយផ្អែកទៅលើមូលដ្ឋាននេះតែម្តង។

---

[51] រឿងក្តីរបស់ *A* និងអ្នកផ្សេងទៀត តទល់នឹង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ (លេខ ២) [២០០៥] UKHL ៧១ [២០០៥] កថាខណ្ឌ ១១២។

[52] សភាជាន់ខ្ពស់, *គំនិតយោបល់របស់ព្រឹទ្ធបុរសទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងសាលក្រមនៅក្នុងរឿងក្តី A(FC) និងអ្នកផ្សេងទៀត (FC) តទល់នឹង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ [២០០៥] UKHL ៧១ កថាខណ្ឌទី ៣៩*។

00374900



## XI. មូលហេតុទី ៦ នៃបណ្តឹងឧទ្ធរណ៍: ការបកស្រាយសន្ធិសញ្ញា ដោយមិនត្រឹមត្រូវ

74. សម្រាប់ហេតុផលទាំងឡាយដែលបានលើកឡើងរួចមកហើយនោះ កសចស បានភ័ន្តច្រឡំនៅក្នុងការបកស្រាយរបស់ខ្លួនទៅលើមាត្រា ១៥ ក្នុងលក្ខណៈមួយដែលនាំឱ្យមានការរំលោភលើគោលបំណងរបស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។

75. អញ្ញត្រកម្មដែលត្រូវបានបង្កើតឡើងនៅក្នុងមាត្រា ១៥ នោះគឺថា ភស្តុតាងដែលដិតដាមដោយអំពើទារុណកម្ម អាចត្រូវបានប្រើប្រាស់ "ប្រឆាំងនឹងជនជាប់ចោទពីបទធ្វើទារុណកម្ម ដែលជាភស្តុតាងបញ្ជាក់ថា ចម្លើយសារភាពនោះត្រូវបានធ្វើឡើង"។ កសចស លើកឡើងថា "វាប្រាកដហើយថា អញ្ញត្រកម្មនេះមិនអនុញ្ញាតឱ្យមានការប្រើប្រាស់ចម្លើយសារភាព ដែលទទួលបានដោយអំពើទារុណកម្ម ដើម្បីប្រឆាំងនឹងជនរងគ្រោះដោយអំពើអំពើទារុណកម្ម ឬប្រឆាំងនឹងជនណាម្នាក់ដែលត្រូវបានចោទប្រកាន់ដោយជនរងគ្រោះនៃអំពើទារុណកម្មនោះទេ"[53]។ ផ្ទុយទៅវិញ នៅក្នុងកថាខណ្ឌទី ២៨ កសចស លើកឡើងបន្ថែមទៀតថា "ដោយមិនគិតពីកាលៈទេសៈនៃព័ត៌មានដែលទទួលបាននៅក្នុងចម្លើយសារភាព នៅត្រឹមដំណាក់កាលនេះ យើងមិនអាចធ្វើការអះអាងថាមិនមានផ្នែកណាមួយនៃការពិតត្រូវបានរកឃើញនៅក្នុងចម្លើយសារភាពទាំងនោះនៅឡើយទេ"។ អាចនិយាយម្យ៉ាងទៀតបានថា កសចស មិនបានច្រានចោលលទ្ធភាពដែលថា ខ្លួននឹងពិតជាសំអាងទៅលើភស្តុតាងដែលបានមកដោយអំពើទារុណកម្មនោះទេ។ នៅក្នុងការអនុវត្តលក្ខខណ្ឌស្តីពី "សច្ចៈភាព" កសចស ភ័ន្តច្រឡំទៅលើបញ្ហានៃភាពអាចទទួលយកបាននូវភស្តុតាងដែលដិតដាមដោយអំពើទារុណកម្ម។

76. វិធីបែបនេះមិនមែនគ្រាន់តែជាការបំពានពាក្យពេចន៍នៃមាត្រា១៥ នៃអនុសញ្ញា អនុសញ្ញា CAT ប៉ុណ្ណោះទេ តែក៏ជាការរំលោភទៅលើគោលបំណងនៃអនុសញ្ញានេះផងដែរ។ ភស្តុតាងដែលដិតដាមដោយអំពើទារុណកម្មមិនអាចឱ្យជឿជាក់បានទេ ហើយនៅក្រោមកាលៈទេសៈណាក៏ដោយ កសចស មិនអាចប្រើប្រាស់ខ្លឹមសារនៃភស្តុតាងបែបនេះបានទេ លើកលែងតែការប្រើប្រាស់ចម្លើយសារភាពបានដោយការធ្វើទារុណកម្ម ប្រឆាំងនឹងជនណាម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម ដើម្បីបង្ហាញថា ចម្លើយសារភាពនោះទទួលបានដោយការធ្វើទារុណកម្មតែប៉ុណ្ណោះ។ ការសំអាងទាំងឡាយទៅលើភស្តុតាងដែលដិតដាមដោយអំពើទារុណកម្ម គឺជាការ

---

[53] កថាខណ្ឌទី ២១ នៃដីកាសម្រេច។

រំលោភទៅលើគោលបំណងនៃមាត្រា ១៥។ ហេតុដូច្នេះ វាជាការភ័ន្តច្រឡំ។ ដីកាសម្រេចនេះ ត្រូវតែបានច្រានចោល ដោយសារមូលហេតុនេះឯង។

## XII. មូលហេតុទី ៧ នៃបណ្តឹងឧទ្ធរណ៍: ទ្រឹស្តីនៃភស្តុតាងដែលបានមកដោយអំពើទុច្ចរិត (FRUIT OF THE POISONOUS TREE DOCTRINE)

77. កសចស លើកឧទាហរណ៍ពីរនៃភស្តុតាង ដែលខ្លួនរកឃើញនៅខាងក្រៅវិសាលភាពនៃមាត្រា ១៥ នៃអនុសញ្ញា អនុសញ្ញា CAT នៅក្នុងកថាខណ្ឌទី ២៧ នៃដីកាសម្រេច។ មូលហេតុនៃបណ្តឹងឧទ្ធរណ៍ [ទី ៧ និង ៨] នឹងត្រូវពាក់ព័ន្ធនឹងអញ្ញត្រកម្មពីរនេះ។

78. អញ្ញត្រកម្មទីមួយ គឺការប្រើប្រាស់ភស្តុតាងបានមកដោយការធ្វើទារុណកម្ម ដែលត្រូវបានគេហៅថា"ភស្តុតាងតម្រុយ)។ មានន័យថា ភស្តុតាងនោះសំអាងទៅលើការស៊ើបអង្កេតបន្ថែមទៀត យុត្តិកម្មនោះគឺថា ["ភស្តុតាងតម្រុយ" ដ៏សន្ធឹកសន្ធាប់ ដែលត្រូវបានប្រើប្រាស់នៅក្នុងការស៊ើបអង្កេតគឺមិនអាចឲ្យជឿជាក់បានរួចស្រេចទៅហើយ][54]។ អាចនិយាយម្យ៉ាងទៀតបានថា ដោយសារតែភស្តុតាងដ៏ក្រាស់ក្រែលដែល កសចស ប្រើប្រាស់នៅក្នុងការស៊ើបអង្កេតមិនអាចឲ្យជឿជាក់បាន នោះមិនមានអញ្ញត្រកម្មណាគួរត្រូវបានធ្វើឡើងចំពោះភស្តុតាងដែលទទួលបានមកដោយការធ្វើទារុណកម្ម ដែលមិនគួរឲ្យជឿជាក់បានរួចស្រេចទៅហើយនោះទេ។

79. មេធាវីការពារក្តីសូមលើកឡើងថា ការដែល កសចស សំអាងទាំងមិនស្របច្បាប់ទៅលើវិធីទទួលបានភស្តុតាងដោយការធ្វើទារុណកម្មនោះ គឺមិនមែនដោយសារតែភស្តុតាងនោះមិនគួរឲ្យជឿជាក់បានរួចទៅហើយនោះទេ តែក៏ដោយសារភស្តុតាងនោះមានសក្តានុពលសម្រាប់វិធីផ្សេងទៀតក្នុងការបន្តការអនុវត្តន៍ដែលឃោរឃៅ និងអមនុស្សធម៌ផងដែរ។ មេធាវីការពារក្តីកត់សម្គាល់ថា ភាពមិនគួរឲ្យជឿជាក់បាននៃភស្តុតាង ដែល កសចស ប្រើប្រាស់ មិនត្រូវបានគេបង្កើតឲ្យបានឡើងពេញលេញនៅឡើយទេ ហើយក៏មិនតម្រូវឲ្យមាននៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីនេះដែរ។ ប៉ុន្តែ ជំហរនេះគឺប្លែកពីគេ និងខុសគ្នាទាំងស្រុងទៅនឹងអ្វីដែល កសចស បានទទួលស្គាល់ថា ឯកសារជាក់លាក់មួយទទួលបានមកដោយការធ្វើទារុណកម្ម។ ហេតុដូច្នេះ កសចស ត្រូវបានហាមឃាត់ចំពោះការប្រើប្រាស់ឯកសារបែបនេះ។

---

[54] កថាខណ្ឌទី ២៧ នៃដីកាសម្រេច។

80. ការពិភាក្សាដេញដោលរបស់គណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្ម នៅក្នុងការបកស្រាយមាត្រា១៥ នៃអនុសញ្ញា អនុសញ្ញា CAT នោះគឺ "មាត្រា ១៥ តម្រូវថាថៅក្រមទាំងឡាយ ត្រូវដកខ្លួនចេញពីការទទួលស្គាល់ភស្តុតាងនៅកន្លែងទីមួយ"[55]។ ហេតុដូច្នេះ ប្រសិនបើ កសចស ទទួលស្គាល់ថា ឯកសារមួយជាប់ជិតដាមដោយអំពើទារុណកម្ម នោះ កសចស មិនត្រូវប្រើប្រាស់ឯកសារនោះទេ វៀលែងតែសម្រាប់អះអាងថា ឯកសារជាក់លាក់មួយត្រូវបានធ្វើឡើង និងជាប់ពាក់ព័ន្ធទៅនឹងជនណាម្នាក់ ដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម ដើម្បីបង្ហាញថា ចម្លើយសារភាពនោះត្រូវបានធ្វើឡើងតែប៉ុណ្ណោះ។

81. ទ្រឹស្តីនៃភស្តុតាងដែលបានមកដោយអំពើទុច្ចរិត លើកឡើងថា ភស្តុតាងដែលត្រូវបានសំអាងទៅលើភស្តុតាងមិនអាចទទួលយកបានកាលពីមុនៗ ក៏មិនអាចទទួលយកបាននៅក្នុងដំណើរការនីតិវិធីនោះដែរ។ គេបានពិចារណាថា បើដើមឈើនោះពុល មានន័យថា ភស្តុតាងអនីត្យានុកូលដំបូង នោះផ្លែៗដែលដុះចេញពីដើមឈើនោះក៏ពុលដែរ។ ហេតុដូច្នោះ ភស្តុតាងដែលត្រូវបានសំអាងទៅលើភស្តុតាងដើមដែលមិនស្របច្បាប់ ក៏មិនអាចទទួលយកបានដូចគ្នានេះដែរ។ ឧទាហរណ៍ ប្រសិនបើ កសចស ប្រើប្រាស់ចម្លើយសារភាពនៅក្នុងការសម្ភាសន៍ស្តាប់យកចម្លើយសាក្សី ហើយឯកសារទាំងនោះប្រឈមមុខទៅនឹងឯកសារមិនស្របច្បាប់ នោះឯកសារនោះធ្វើឲ្យប្រឡាក់ប្រឡូកដល់សាក្សី ហើយភស្តុតាងបានពីសាក្សីដែលសំអាងទៅលើខ្លឹមសារនៃចម្លើយសារភាពបែបនោះ គឺមិនអាចឲ្យជឿជាក់បានឡើយ។

82. ទ្រឹស្តីនេះក៏ត្រូវបានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌបារាំងផងដែរ ដែលតុលាការកំពូលបានលើកឡើងថា រាល់អំពើដែលកើតចេញពីការរឹបអូសដោយខុសច្បាប់ ក៏ត្រូវចាត់ទុកជាមោឃៈផងដែរ[56]។ ឧទាហរណ៍ មោឃភាពនេះត្រូវគ្របដណ្តប់ដល់កំណត់ហេតុស្តាប់ចម្លើយសាក្សី ទាក់ទងទៅនឹងភស្តុតាងដែលប្រមូលបានពីការរឹបអូសដោយខុសច្បាប់[57]។ មោឃភាពនៃការរឹបអូសបែបនេះនាំឲ្យមានមោឃភាពដល់ភស្តុតាងដែលបានរឹបអូសបាន ព្រមទាំងកិច្ចស៊ើបសួរដែលសំអាងទៅលើភស្តុតាងបែបនោះ។ ទាក់ទងទៅនឹងទ្រឹស្តីនេះផងដែរ នៅក្នុងច្បាប់បារាំង គឺការធ្វើមោឃភាពការសម្ភាសន៍សួរយកចម្លើយពីជនសង្ស័យ ដែលបានធ្វើឡើងដោយការសណ្តំទៅលើសាក្សី។ របាយការណ៍អ្នកជំនាញ និងរបាយការណ៍ជាប់ពាក់ព័ន្ធទៅនឹងការសម្ភាសន៍បែបនោះក៏ត្រូវបាន

---

[55] CAT/C/SR.307 ចុះថ្ងៃទី ២៨ វិច្ឆិកា ១៩៩៧ កថាខណ្ឌទី ៥៥។

[56] Crim, 10 décembre 1968, *Bull.* 333; Crim, 4 juin 1969, *Bull.* 186.

[57] Crim, 4 juin 1997, *Bull.* 221.

ចាត់ទុកជាមោឃៈផងដែរ ដោយសាររបាយការណ៍ទាំងពីរនេះសំអាងទៅលើការសម្អាតសន៍បែប នោះ[58]។ ដូចគ្នាទៅនឹងអំពើទារុណកម្មផងដែរ ការសណ្ដំចិត្តគឺជាទម្រង់សួរយកចម្លើយមួយ ដែលខុសច្បាប់ ទោះបីជាមានការរំលោភបំពានតិចយ៉ាងណាក៏ដោយ។

83. គណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្មបានកត់សម្គាល់ថា ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម 'fruit of torture' ក៏ស្ថិតនៅក្រោមការហាមឃាត់នៃមាត្រា១៥ នៃអនុសញ្ញា CAT ផងដែរ និងបានរិះគន់យ៉ាងខ្លាំងចំពោះរដ្ឋដែលអនុញ្ញាតឱ្យមានការទទួលយកភស្តុតាងដែលជិតដាម ដោយអំពើទារុណកម្ម[59]។ អ្នកធ្វើអត្ថាធិប្បាយមួយរូបពន្យល់ថា គណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្មមិនបានញែក "រវាងភស្តុតាងក្លាយ (derivative evidence) ដែលមានតម្លៃបញ្ជាក់អះអាង ឱ្យដាច់ពីភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម និងភស្តុតាងក្លាយដែលមិនមានតម្លៃបញ្ជាក់អះអាងនោះឡើយ"[60]។

84. អញ្ញត្រកម្មនៅក្នុងមាត្រា ១៥ មានកម្រិត និងមិនបានបង្កើតជាអញ្ញត្រកម្មមួយចំពោះទ្រឹស្តីនៃភស្តុតាងដែលបានមកដោយភាពទុច្ចរិតនោះទេ។ តាមរយៈនេះ អ្នកធ្វើអត្ថាធិប្បាយមួយរូបបានលើកឡើងនៅក្នុងការពិភាក្សាពីអញ្ញត្រកម្ម ដែលបានចែងក្នុងបទប្បញ្ញត្តិនោះថា៖

> វិធាននៃមាត្រា ១៥ បញ្ជាក់ន័យថា ភស្តុតាងដែលបានដោយទុច្ចរិត មិនគួរយកមកប្រើប្រាស់ជាភស្តុតាងនោះទេ។ មានន័យថា ខ្លឹមសារនៃចម្លើយសារភាព ឬចម្លើយសារភាពដទៃទៀតដែលទទួលបានដោយអំពើទារុណកម្ម[61]។

---

[58] Crim, 28 novembre 2001, *Bull.* 248.

[59] សូមមើល CAT/C/SR.250 ផ្នែក D កថាខណ្ឌទី ១៨ ដែលគណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្ម "ផ្តល់អនុសាសន៍ថា បទប្បញ្ញត្តិពិសេសអាចត្រូវបានដាក់បញ្ចូលទៅក្នុងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋជាភាគី ទាក់ទងទៅនឹងការដកចេញពីដំណើរការនីតិវិធីតុលាការទៅលើភស្តុតាង ដែលទទួលបានដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដែលជាបច្ច័យពីការធ្វើទារុណកម្ម ដូចដែលមានចែងនៅក្នុងមាត្រាទី ១៥ នៃអនុសញ្ញានេះ (មានបន្ថែមសេចក្តីបញ្ជាក់)។ CAT/C/SR.279 កថាខណ្ឌទី ១៥ នៃអនុសាសន៍ ដែលគណៈកម្មាធិការផ្តល់យោបល់ថា "ចម្លើយសារភាពដែលទទួលបានដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នៅក្រោមអំពើទារុណកម្មមិនត្រូវបង្កើតទៅជាភស្តុតាងនៅក្នុងតុលាការឡើយ"។

[60] R. Pattenden, "ការទទួលយកភស្តុតាង ដែលទទួលបានពីអំពើទារុណកម្ម ដោយតតីយភាគី" នៅក្នុងព្រឹត្តិប័ត្រអន្តរជាតិស្តីពីភស្តុតាង & វត្ថុតាង (២០០៦) ទំព័រទី ៩។

[61] M. Nowak & E. McArthur, អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម។ វិចារណកថា (*Commentary*) ក្នុងឆ្នាំ ២០០៨ ទំព័រទី ៥៣៦។

85. វិធានដែលថា ចម្លើយសារភាព ឬកំណត់ហេតុសួរចម្លើយទទួលបានដោយអំពើទារុណកម្ម មិនគួរយកមកប្រើប្រាស់ជាភស្តុតាងនោះ ក៏ត្រូវបានទទួលយកនៅក្នុងយុត្តិសាស្ត្រអន្តរជាតិ និងយុត្តាធិការផងដែរ[62]។

86. ដូច្នោះ ការប្រើប្រាស់ស្តុតាងដែលបានមកដោយអំពើទារុណកម្ម សម្រាប់គោលបំណងនៃភស្តុតាងតម្រុយ គឺនាំឱ្យរំលោភទៅលើទ្រឹស្តីនៃភស្តុតាងបានមកដោយអំពើទុច្ចរិត ដែលរំលោភទៅលើមាត្រា១៥នៃអនុសញ្ញា CAT ។ ដូចនោះ ភស្តុតាងដែលសំអាងទៅលើភស្តុតាងបានមកដោយអំពើទារុណកម្ម គឺត្រូវបានជាប់ដិតដាម និងមិនអាចទទួលយកនៅក្នុងដំណើរការនីតិវិធីបានឡើយ។ អាស្រ័យហេតុនេះ ចម្លើយសារភាពបែបនេះមិនអាចយកមកប្រើប្រាស់ជាភស្តុតាងតម្រុយសម្រាប់ការស៊ើបអង្កេតរបស់ កសចស បានឡើយ។

## XIII. មូលហេតុទី ៨ នៃបណ្តឹងឧទ្ធរណ៍: មិនអនុញ្ញាតឱ្យសំអាងនៅលើខ្លឹមសារនៃចម្លើយសារភាពទេ

### ១៣.១ អំណះអំណាងមិនត្រឹមត្រូវ

87. អញ្ញត្រកម្មទីពីរដែល កសចស តាក់តែងឡើង គឺផ្ទុយទៅនឹងមាត្រា១៥ នៃអនុសញ្ញា CAT គឺជាចំនុចដែល កសចស លើកឡើងថា ខ្លួនឯងផ្ទាល់មិនប្រើប្រាស់ "ព័ត៌មានដែលទទួលបាន [...] ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវពិតប្រាកដនៃខ្លឹមសារនោះទេ ប៉ុន្តែ គឺគ្រាន់តែជាបង្ហាញថាបក្សកុម្មុយនីស្តកម្ពុជាបានប្រើប្រាស់ខ្លឹមសារនៃចម្លើយសារភាពទាំងនោះ"[63]។

88. មេធាវីការពារក្តីសូមលើកឡើងដោយគោរពថា ការវែកញែកនេះគឺមិនមានសុពលភាពទេ ដោយសារថាការសំអាងត្រូវយោងទៅលើខ្លឹមសារនៃចម្លើយសារភាពទាំងនោះ ដើម្បីបញ្ជាក់អះអាងអំពីរបៀបដែលជនត្រូវចោទបានប្រើប្រាស់ព័ត៌មាន ដែលមាននៅក្នុងចម្លើយសារភាព នៅក្នុងទម្រង់

---

[62] សូមមើល យុត្តិសាស្ត្រផ្សេងៗនៃអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម នៅទូទាំងបណ្តឹងឧទ្ធរណ៍នេះ និងនៅក្នុងរឿងក្តីរវាង A និងអ្នកផ្សេងទៀត តទល់នឹង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ (លេខ ២) [២00៥] UKHL ៧១ [២00៥] 3 WLR 1249 ដែលជាឧទាហរណ៍ជាក់ស្តែងបំផុតនៃការអនុវត្តន៍ទ្រឹស្តីនេះ នៅក្នុងយុត្តាធិការជាតិ។ សរុបសេចក្តីមក រឿងក្តីនេះសំអាងទៅលើករណីផ្សេងទៀតពីយុត្តាធិការជាតិ។

[63] កថាខណ្ឌទី ២៧ នៃដីកាសម្រេច។

នៃបក្សកុម្មុយនីស្តកម្ពុជា។ វិធីនេះគឺហួសពីអញ្ញត្រកម្មកំណត់ ដែលមានចែងនៅក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម។ ដូច្នេះ ដីកាសម្រេចនេះត្រូវតែច្រានចោល។

## ១៣.២ ភាពមិនអាចឲ្យជឿជាក់បាន រារាំង កសចស មិនឲ្យសំអាងនៅលើខ្លឹមសារ

89. នៅក្នុងកថាខណ្ឌទី ២៨ នៃដីកាសម្រេច កសចស កាន់តែបញ្ជាក់ជាទូទៅថែមទៀតថា ខ្លួនសំអាងទៅលើខ្លឹមសារនៃចម្លើយសារភាព និងលើកឡើងថា៖

> ក្រៅពីចំនុចនេះដែលថា មានព័ត៌មាននៅក្នុងចម្លើយសារភាពត្រូវបានទទួលដោយការប្រព្រឹត្តអំពើទារុណកម្មនោះ នៅត្រឹមដំណាក់កាលនេះ យើងអាចត្រឹមតែអះអាងថា មិនមានព័ត៌មានណាមួយដែលបានបង្ហាញពីការពិតនៅក្នុងចម្លើយសារភាពទាំងនោះនៅឡើយទេ។ ការវាយតម្លៃអំពីភាពគួរឲ្យជឿជាក់បានអាចធ្វើទៅបាន បន្ទាប់ពីការបិទកិច្ចស៊ើបសួរតែប៉ុណ្ណោះ គឺនៅពេលដែលសំណុំរឿងពេញលេញគ្រប់គ្រាន់។

90. ដូច្នេះ កសចស បំពានទស្សនទាននៅពីក្រោយការហាមឃាត់នៃមាត្រា១៥៖ ភាពដែលមិនគួរឲ្យជឿជាក់បានដែលមានជាប់មកជាមួយភស្តុតាងទទួលបានដោយការធ្វើទារុណកម្ម និងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សរបស់អារិយប្រទេសដែលថា ភស្តុតាងមិនគួរបានមកដោយវិធីធ្វើទារុណកម្មនោះទេ។ ឯកសារជាច្រើនដែលមានរយៈពេល ៣០ ឆ្នាំមកហើយ គឺទទួលបានដោយការធ្វើទារុណកម្មទាំងបង្ខំ ហើយក្នុងករណីខ្លះ ត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថាឯកសារនោះត្រូវបានចងក្រងឡើងដោយអ្នកសួរចម្លើយ[64]។ ថ្នាក់ដឹកនាំបក្សត្រូវបានគេរាយការណ៍ថាមានការសង្ស័យពីភាពគួរឲ្យជឿទុកចិត្តបាននៃចម្លើយសារភាពខ្លះដែលទទួលបានមកនោះ[65]។

---

[64] ឌុច ពន្យល់ថា "ខ្ញុំនៅចាំបាន ថាតើចម្លើយសារភាពត្រូវបានគេសម្រេចដោយរបៀបណានោះ។ ដូច្នេះ ខ្ញុំសូមជូនឧទាហរណ៍មួយ ថាតើចម្លើយសារភាពត្រូវបានគេលាបពណ៌ដោយរបៀបណា នៅពេលដែលគេចង់ចាប់អ្នកណាម្នាក់នោះ។ ពេលនោះគេចង់ឲ្យចម្លើយសារភាពឈានដល់ចំនុចនោះ"។ សូមមើល សំណុំរឿង ០០១ ប្រតិចារឹក ចុះថ្ងៃទី ១៨ ឧសភា ២០០៩ ឯកសារលេខ E1/20.1/TR001ទំព័រទី ៥៦ (បន្ទាត់ទី ១៩) ទំព័រទី ៥៧ (បន្ទាត់ទី ២)។

[65] ឌុច បានលើកឡើងនៅក្នុងតុលាការថា "ទោះជាយ៉ាងណាក៏ដោយ ពេលមួយ ប៉ុល ពត មិនទាំងជឿថាចម្លើយសារភាពនោះគឺជាព័ត៌មានពិតនោះទេ"។ សូមមើល សំណុំរឿង ០០១ ប្រតិចារឹក ចុះថ្ងៃទី ១៦ មិថុនា ២០០៩ ឯកសារលេខ E1/20.1/TR001ទំព័រទី ៥០ (បន្ទាត់ទី ១០ ដល់ ១២) ។

00374906



91. មេធាវីការពារក្តីសូមលើកឡើងថា កសចស មិនអាចបញ្ជាក់អះអាងពី"ការពិត"ពីចម្លើយសារភាពទាំងនេះបានទេ។ ដូចទទួលសារភាពថា ដំណើរការបញ្ជាក់ការពិតទាំងនោះមិនអាចទាំងឲ្យគាត់ជឿបានផង[66] ហើយលើសពីនេះទៅទៀត ដំណើរការបញ្ជាក់អះអាងទាំងនោះគឺផ្ទុយទៅនឹងការហាមឃាត់នៃមាត្រាទី ១៥ ទៀតផង។

92. សេចក្តីសម្រេចរបស់ កសចស គឺជាការរំលោភដោតផ្ទាល់ទៅនឹងមាត្រា ១៥ នៃអនុសញ្ញា CAT ហើយបើអញ្ចឹងទេ ដីកាសម្រេចនេះគួរតែត្រូវបានច្រានចោល។

## ១៣.៣ ភាពគួរឲ្យជឿជាក់បាន មិនមែនជាការពិចារណានោះទេ

93. កថាខណ្ឌទី ២៨ នៃដីកាសម្រេចបញ្ជាក់សេចក្តីថា កសចស ខ្លួនឯងពិតជាអាចធ្វើការវាយតម្លៃពីភាពគួរឲ្យជឿជាក់បាននៃខ្លឹមសារទាំងនោះ នៅពេលខ្លួននិយាយថា "ត្រឹមដំណាក់កាលនេះ យើងអាចត្រឹមតែធ្វើការអះអាងថា មិនមានព័ត៌មានណាមួយ ដែលបានបង្ហាញពីការពិតនៅក្នុងចម្លើយសារភាពទាំងនោះនៅឡើយទេ"។ មេធាវីការពារសូមលើកឡើងថា វាមិនជាប់ពាក់ព័ន្ធអ្វីនោះទេ បើទោះបីជាអាច ឬមិនអាចក៏ដោយ ដោយសារថា កសចស ត្រូវបានហាមឃាត់ពីការចូលពាក់ព័ន្ធអនុវត្តនេះ ក្នុងករណីចម្លើយសារភាពទាំងនោះទទួលបានមកដោយការធ្វើទារុណកម្ម។ លោក Pattenden កត់សំគាល់ថា មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម "ដាក់កាតព្វកិច្ចឲ្យប្រទេសហត្ថលេខីទាំងអស់នៃអនុសញ្ញានេះ "ធានា" ថា គ្មានចម្លើយសារភាពណាមួយធ្វើឡើងនៅក្រោមអំពើទារុណកម្មត្រូវបានទទួលយកនោះឡើយ[67] <u>ទោះជាគួរឲ្យជឿជាក់បានដោយរបៀបណាក៏ដោយ</u> [...]"។

94. អាស្រ័យហេតុនេះ ភាពគួរឲ្យជឿជាក់បានមិនមែនជាចំនុចមួយ ដែលអាចយកមកពិចារណានៅក្នុងការវាយតម្លៃភស្តុតាងដែលជិតដាមដោយអំពើទារុណកម្មនោះទេ។ កសចស មិនអាចស្រាវ

---

[66] ឌុច និយាយថា "ខ្ញុំអាចសរុបបានថា ខ្ញុំមិនមានអ្វីយកមកថ្លឹងថ្លែងថាតើសម្លើយសារភាពទាំងនោះពិត ឬមិនពិតនោះបានទេ"។ សូមមើល សំណុំរឿងលេខ ០០១, ប្រតិចារឹក ចុះថ្ងៃទី ១៨ ឧសភា ២០០៩, ឯកសារលេខ E1/20.1/TR001, ទំព័រទី ៥១ (បន្ទាត់ទី ១ ដល់ ៣)។

[67] R. Pattenden, "ការទទួលយកភស្តុតាងដែលបានយកដោយការធ្វើទារុណកម្មនៃភាគីទីបី" នៅក្នុង *"ព្រឹត្តិប័ត្រអន្តរជាតិស្តីពីភស្តុតាង និងសក្ខីកម្ម (២០០) ទំព័រទី ៦* (មានបន្ថែមសេចក្តីបញ្ជាក់)។

ជ្រាវផ្នែកដែលគួរឲ្យជឿជាក់បាននៅក្នុងចម្លើយសារភាពទាំងនោះទេ។ ជាលទ្ធផលនៃចំនុចនេះ ដីកាសម្រេចគួរត្រូវបានច្រានចោល។

## XIV. មូលហេតុទី ៩ នៃបណ្តឹងឧទ្ធរណ៍: ការដាក់កម្រិតនៃការប្រើប្រាស់ចំណារ និងប្រវត្តិរូប

95. នៅក្នុងកថាខណ្ឌទី ១៩ នៃដីកាសម្រេច កសចស លើកឡើងថា "ចំណារសរសេរដៃដែលមាននៅក្នុងចម្លើយសារភាព"និង"ប្រវត្តិរូបបឋម" មិនថិតនៅក្រោមមាត្រា១៥ នៃអនុសញ្ញា CAT នោះទេ ដោយហេតុថា វាមិនមែនបានមកដោយសារលទ្ធផលនៃការធ្វើទារុណកម្មនោះទេ។

96. ក្នុងករណីដែលដឹងថា ចំណារ និងព័ត៌មានពីប្រវត្តិរូបបឋម មិនត្រូវបានបន្ថែម ឬធ្វើឡើងដោយអំពើទារុណកម្ម នោះមេធាវីការពារក្តីសូមលើកឡើងថា ព័ត៌មាននោះអាចត្រូវបានសំអាងដោយមានកម្រិត ប្រសិនបើវាមិនតម្រូវឲ្យមាន ឬយោងទៅលើអំណះអំណាងទាំងឡាយនៅក្នុងខ្លឹមសារនៃ"ចម្លើយសារភាព"នោះទេ។ ការប្រើប្រាស់ដោយការសំអាងទៅខ្លឹមសារនៃចម្លើសារភាពទាំងនោះគឺត្រូវបានហាមឃាត់ដោយមាត្រា១៥។

## XV. មូលហេតុទី ១០ នៃបណ្តឹងឧទ្ធរណ៍: នៅពេលណា/ដោយអ្នកណា ដែលអំពើទារុណកម្មបានកើតឡើង គឺមិនពាក់ព័ន្ធទេ

97. នៅក្នុងអក្សរក្នុងលេខយោងទី ៣០ នៃដីកា, កសចស បញ្ជាក់ថា "ចម្លើយសារភាពដ៏ចំរូងចម្រាសដែលមានអាយុកាលជាង ៣០ ឆ្នាំមកហើយនោះ មិនមែនបានមកដោយអង្គជំនុំជម្រះវិសាមញ្ញ ឬអាជ្ញាធរណាមួយដែលដើរតួនាទីជំនួយឲ្យអង្គជំនុំជម្រះវិសាមញ្ញនោះឡើយ"។ មេធាវីការពារក្តីសូមលើកឡើងថា: វាមិនមានការពាក់ព័ន្ធដែលថា អាជ្ញាធរណាដើរតួជំនួសនៅអំឡុងពេលពាក់ព័ន្ធនោះ ហើយចម្លើយសារភាពនោះមិនអាចទទួលយកបានទេ ទោះបីជាអំពើទារុណកម្មនោះត្រូវបានប្រព្រឹត្តឡើងនៅពេលណា និងដោយអ្នកណាក៏ដោយ។

98. នៅក្នុងសេចក្តីសម្រេចរបស់សភាជាន់ខ្ពស់ក្នុងរឿងក្តី *A និងអ្នកផ្សេងទៀត តទល់នឹង SSHD* (លេខ ២) គេបានលើកឡើងពីមតិយោបល់របស់ចៅក្រម Neuberger នៅក្នុងសាលាឧទ្ធរណ៍ថា

មាត្រា១៥ អនុវត្តនៅគ្រប់ទីកន្លែងដែលអំពើទារុណកម្មត្រូវបានប្រព្រឹត្តឡើង[68]។ នៅក្នុងការពន្យល់ពីមាត្រា១៥ នៃអនុសញ្ញា CAT គណៈកម្មាធិការប្រយុទ្ធប្រឆាំងនឹងអំពើទារុណកម្មបានសង្កត់ធ្ងន់ថា ភស្តុតាងដែលបានមកដោយអំពើទារុណកម្ម គឺមិនអាចទទួលយកជាស្វ័យប្រវត្តិ ហើយមិនគួរផ្តល់អំណាចឆន្ទានិសិទ្ធិទៅឲ្យចៅក្រម ដើម្បីបញ្ជាក់អះអាងពីភស្តុតាងដែលបានមកដោយអំពើទារុណកម្មនោះទេ[69]។

99. ស្នងការទទួលសិទ្ធិមនុស្សអឺរ៉ុប បានមានប្រសាសន៍នៅក្នុងរបាយការណ៍មួយស្តីពីចក្រភពអង់គ្លេសថា "អំពើទារុណកម្ម គឺជាអំពើទារុណកម្ម ទោះជាអ្នកណាប្រព្រឹត្តក៏ដោយ ហើយដំណើរការនីតិវិធីរបស់តុលាការ គឺជាដំណើរការនីតិវិធីរបស់តុលាការ ទោះជាដំណើរការនីតិវិធីនោះមានគោលបំណងដូចម្តេចក៏ដោយ។ អំពើទារុណកម្មមិនអាចទទួលយកមកដាក់ចូលក្នុងដំណើរការនីតិវិធីបានទេ"[70]។

100. ចំណែកឯ កសចស បានកត់សម្គាល់ថា ភស្តុតាងនោះមានអាយុកាលប្រហែល ៣០ ឆ្នាំទៅហើយ ហើយមិនបានទទួលមកដោយអាជ្ញាធរណាមួយរបស់ អវតក នោះ គឺមិនជាជាប់ទាក់ទិននោះទេ និងមិនបដិសេធចំពោះការដែលថា ភស្តុតាងនោះគឺមិនអាចទទួលយកបានជាដាច់ខាត។ ហេតុនេះត្រូវតែច្រានចោលដីកាសម្រេចនេះ។

## XVI. មូលហេតុទី ១១ នៃបណ្តឹងឧទ្ធរណ៍: ការបកស្រាយមិនត្រឹមត្រូវរបស់ឧស្សនជាន់នៃមាត្រា ១៥

[68] ចៅក្រម Neuberger នៅក្នុងរឿងក្តីរបស់ *A និងអ្នកផ្សេងទៀត តទល់នឹង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ (លេខ ២)* [២០០៤] WECA Civ 1123, [2005] 1 WLR 414 at [448], *per* Neuberger LJ, យោងនៅក្នុង: R. Pattenden, "ការទទួលយកភស្តុតាងដែលបានមកដោយអំពើទារុណកម្ម ដោយតតីយភាគី" នៅក្នុង: *ព្រឹត្តិប័ត្រអន្តរជាតិស្តីពីភស្តុតាង និងសក្ខីកម្ម (២០០៦) ទំព័រទី ១០*។ សូមមើលការវិភាគមួយនៃរឿងក្តីរបស់ *A* និងអ្នកផ្សេងទៀត តទល់នឹង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, T. Thienel "អំពើទារុណកម្មរបស់ជនបរទេស និងការទទួលយកភស្តុតាង'Foreign Acts of Torture and the Admissibility of Evidence'" នៅក្នុងព្រឹត្តិប័ត្រស្តីពីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ៤ (២០០៦) ទំព័រទី ៤០១-៤០៩។

[69] CAT/C/CR/30/6 (2003), នៅក្រោមប្រធានបទ-C ស្តីពី ការព្រួយបារម្ភ កថាខណ្ឌទី ៥ នៅក្រោម (០)។ សូមមើលផងដែរ CAT/C/SR.494, កថាខណ្ឌទី ៣៣ និង A/48/44, កថាខណ្ឌទី ១៤៨។

[70] លោក Alvaro Gil-Robles, ក្រុមប្រឹក្សានៃស្នងការសិទ្ធិមុស្សអឺរ៉ុប (the Council of European Commissioner for Human Rights) បានដកស្រង់សម្តីនៅក្នុង R. Pattenden "ការទទួលយកភស្តុតាងដែលបានមកដោយអំពើទារុណកម្មដោយតតីយភាគី" នៅក្នុង: *ព្រឹត្តិប័ត្រអន្តរជាតិស្តីពីភស្តុតាង និងសក្ខីកម្ម (២០០៦) ទំព័រទី ១២*។

00374909



101. ក្នុងការបកស្រាយពីមូលហេតុចម្បងក្រោមមាត្រា១៥នៃអនុសញ្ញា CAT កសចស លើកឡើងថា៖

> ទាក់ទងទៅនឹងមូលហេតុចម្បងទីមួយ នៅក្រោមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម នៅក្នុងបរិបទនេះ ការហាមឃាត់មិនឱ្យប្រើប្រាស់ភស្តុតាងបែបនោះ គឺមិនត្រឹមតែមិនធ្វើបានឱ្យអ្នកប្រព្រឹត្តអំពើទារុណកម្មរាងចាលប៉ុណ្ណោះទេ តែផ្ទុយទៅវិញ វាបែរជាអនុញ្ញាតឱ្យជនដែលរងការចោទប្រកាន់ពីបទទារុណកម្ម ប្រើប្រាស់បទប្បញ្ញត្តិច្បាប់នេះ ដើម្បីគេចខ្លួនពីការទទួលសុខត្រូវខាងព្រហ្មទណ្ឌរបស់ខ្លួនទៅវិញ។ ដូច្នេះ ការបកស្រាយបទប្បញ្ញត្តិនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្មតាមន័យត្រង់ៗ អាចត្រឡប់ទៅជាការពារជនដែលប្រព្រឹត្តអំពើទារុណកម្មយ៉ាងពេញទំហឹង និងអាចជាការជម្រុញទឹកចិត្ត ជាជាងការបង្ការកុំឱ្យមានការអនុវត្តគោលនយោបាយធ្វើទារុណកម្មទៅវិញ ព្រមទាំងធ្វើឱ្យខូចខាតដល់គោលបំណងនៃមាត្រា ១៥ ក៏ដូចជាអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្មនេះទាំងមូល[71]។

102. មេធាវីការពារក្តីសូមដាក់ជូននូវការជំទាស់តវ៉ានេះ ដើម្បីជាការឆ្លើយតបទៅនឹងការយល់ច្រឡំមាត្រា ១៥ នៃអនុសញ្ញា CAT ទាំងស្រុង។ ការយល់ច្រឡំនេះ គឺផ្ទុយទៅនឹងការបកស្រាយបទប្បញ្ញត្តិនេះ ដូចដែលបានពន្យល់ដោយគណៈកម្មាធិការប្រយុទ្ធប្រឆាំងនឹងអំពើទារុណកម្ម ព្រមទាំងតុលាការជាតិជាច្រើន។

103. កសចស លើកឡើងថា ការបកស្រាយមាត្រា ១៥ តាមន័យអក្ខរានុរូប អាចក្លាយទៅជាការការពារជនប្រព្រឹត្តអំពើទារុណកម្ម ពីការទទួលខុសត្រូវជាពុំខាន។ ផ្ទុយទៅវិញ វាជាការពិត។ សង្គមជឿនលឿនជាច្រើនបានព្យាយាមតាមរយៈច្បាប់ជាតិរបស់ខ្លួន និងតាមរយៈមធ្យោបាយនៃការអភិវឌ្ឍន៍ច្បាប់អន្តរជាតិ ព្រមទាំងសន្ធិសញ្ញា ដើម្បីផ្តន្ទាទោសការប្រើប្រាស់អំពើទារុណកម្ម ទោះជាក្នុងគោលបំណងណាក៏ដោយ និងដើម្បីធានាថា វិធីដ៏អមនុស្សធម៌ ឃោរឃៅ និងអាក្រក់ក្រៃលែងបែបនេះកើតមានឡើង នោះព័ត៌មានដែលទទួលបាន មិនត្រូវបានយកមកប្រើប្រាស់នោះឡើយ។ កសចស យល់ច្រឡំនៅក្នុងការទទួលស្គាល់ចំនុចនេះ។

104. គេរំពឹងថា អវតក នឹងដាក់ចេញនូវឧទាហរណ៍មួយ និងបន្សល់ទុកកេរ្តិ៍ដំណែលដល់អ្នកប្រកបវិជ្ជាជីវៈច្បាប់នៅក្នុងប្រទេសកម្ពុជា ព្រមទាំងប្រជាពលរដ្ឋជាច្រើនរបស់ប្រទេសនេះ។ ប្រទេសកម្ពុជាជាប្រទេសមួយ ដែលការអនុវត្តន៍អំពើទារុណកម្មមិនទាន់បានលប់បំបាត់ចោលនៅឡើយទេ។

---

[71] កថាខណ្ឌទី ២៤ នៃដីកាសម្រេច (លេខយោងចុងទំព័រត្រូវបានលប់ចោល)។

ប៉ុន្មានឆ្នាំកន្លងមកនេះ គណៈកម្មធិការប្រឆាំងនឹងអំពើទារុណកម្មបានផ្តល់យោបល់ដល់ប្រទេសកម្ពុជាថា ប្រទេសកម្ពុជាពុំគប្បីប្រើប្រាស់ភស្តុតាងដែលបានមកដោយការអនុវត្តន៍ការធ្វើទារុណកម្មនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌរបស់ខ្លួននោះទេ[72]។

105. របាយការណ៍មួយស្តីពីស្ថានភាពនៅប្រទេសកម្ពុជា លើកឡើងថា៖ "អំពើទារុណកម្មនៅតែបន្តកើតមាននៅក្នុងប្រទេសកម្ពុជា ដោយសារតែប្រទេសនេះអនុញ្ញាតឲ្យមាន។ អ្នកប្រព្រឹត្តអំពើទារុណកម្មដឹងថា ពួកគេមិនទំនងជាទទួលរងការផ្តន្ទាទោសនោះទេ។ ច្បាប់ជាច្រើនត្រូវបានគេអនុវត្តយ៉ាងតិចតួចបំផុត។ មានឱកាសជាច្រើនដើម្បីជៀសវាងអំពើទារុណកម្ម"[73]។ របាយការណ៍លើកឡើងបន្ថែមទៀតថា៖

> រដ្ឋាភិបាល និងតុលាការ គឺជាអ្នកសមគំនិតចម្បងជាងគេចំពោះអំពើទារុណកម្មនៅក្នុងប្រទេសកម្ពុជា។ ពួកគេបណ្តោយឲ្យមានអំពើទារុណកម្ម ដោយមិនធ្វើការស៊ើបអង្កេត និងចោទប្រកាន់ឲ្យបានគ្រប់គ្រាន់ចំពោះករណីធ្វើទារុណកម្ម។ វាហាក់មិនមានស្ថាប័នឯករាជ្យ ដែលមានឆន្ទៈ ឬអាចឲ្យក្រុមជនធ្វើទារុណកម្មដែលមានអំណាច ដូចជា នគរបាល ទាហាន និងភ្នាក់ងាររដ្ឋាភិបាលដទៃទៀតទទួលខុសត្រូវចំពោះមុខច្បាប់បាននោះទេ។ ការខ្វះអំណាចឆន្ទៈខាងនយោបាយ ដើម្បីពង្រឹងឯករាជ្យភាព និងវិជ្ជាជីវៈតុលាការ នៅក្នុងចំណោមកំណែទម្រង់ចាំបាច់ដទៃទៀត គឺជារបាំងធំបំផុតដល់ការផ្លាស់ប្តូរស្ថានភាពនេះ។
>
> អំពើទារុណកម្មត្រូវបានប្រព្រឹត្តជារឿយៗ ដោយសារិយាបទនៃការទទួលយកដូចមុនដដែល គឺមានន័យថា ការដែលគេជឿថាទារុណកម្ម អំពើហិង្សា និងការកេងប្រវ័ញ្ចដទៃទៀត និងបទល្មើសពាក់ព័ន្ធ ដូចជា អំពើពុករលួយ និងការជំរិតទារប្រាក់ គឺជារឿង"ធម្មតា" ហើយរំពឹងថានឹងកើតមានឡើង[74]។

---

[72] គណៈកម្មធិការប្រឆាំងនឹងអំពើទារុណកម្ម, សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មធិការប្រឆាំងនឹងអំពើទារុណកម្ម: ប្រទេសកម្ពុជា ថ្ងៃទី ២៧ ឧសភា ២០០៣, ឯកសារលេខ CAT/C/CR/30/2 (សេចក្តីសង្កេតការណ៍/មតិយោបល់សរុប "Concluding Observations/Comments") កថាខណ្ឌទី ៦ នៅក្រោម ចំនុច (ជ) និងកថាខណ្ឌទី ៧ នៅក្រោមចំនុច (ច)។

[73] J. Barber, "អន់ជាងមនុស្ស (Less than Human)។ អំពើទារុណកម្មនៅក្នុងប្រទេសកម្ពុជា ខែមិថុនា ឆ្នាំ ២០០០ ទំព័រទី ១៤៤ (របស់អង្គការទស្សនៈពិភពលោក)"។

[74] J. Barber, "អន់ជាងមនុស្ស (Less than Human)។ អំពើទារុណកម្មនៅក្នុងប្រទេសកម្ពុជា ខែមិថុនា ឆ្នាំ ២០០០ ទំព័រទី ១៤៥ (របស់អង្គការទស្សនៈពិភពលោក)"។

00374911



106. របាយការណ៍មួយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប ឆ្នាំ ២០០៨ លើកឡើងជាក់ច្បាស់ពីការអនុវត្តន៍ការប្រើប្រាស់ចម្លើយសារភាពដោយបង្ខំ នៅក្នុងតុលាការព្រហ្មទណ្ឌកម្ពុជា៖

> កាលពីមុនៗ ចម្លើយសារភាពមិនអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ការផ្តន្ទាទោសបានទេ វៀលែងតែវាស៊ីសង្វាក់គ្នាទៅនឹងភស្តុតាងដទៃទៀត។ ការធានាបៀបនេះ ត្រូវបានដកចេញ ដោយផ្តល់ទម្ងន់ដល់ចម្លើយសារភាព ដូចគ្នាទៅនឹងភស្តុតាងដទៃទៀត (មាត្រា ៣២១) ទោះបីជា PPC និយាយដដែលឡើងវិញពីការហាមឃាត់ទៅលើការប្រើប្រាស់ចម្លើយសារភាពដោយបង្ខំក៏ដោយ។ មានការសំអាងយ៉ាងខ្លាំងទៅលើចម្លើយសារភាព ហើយមានចម្លើយសារភាពជាច្រើនទទួលបានដោយការបង្ខិតបង្ខំ ឬដោយអំពើទារុណកម្ម។ ច្បាប់ថ្មីនេះអាចធ្វើឱ្យអន្តរាយដល់ការហាមឃាត់មិនឱ្យប្រប្រាស់ភស្តុតាង ដែលបានមកដោយការបង្ខំឱ្យសារភាព ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម[75]។

107. របាយការណ៍ទាំងនេះ ព្រមទាំងរបាយការណ៍ដទៃទៀត[76] បញ្ជាក់ថា អំពើទារុណកម្មនៅមានជាច្រើនក្នុងប្រទេសកម្ពុជា ហើយចម្លើយសារភាពដោយបង្ខំក៏កំពុងត្រូវបានប្រើប្រាស់នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដែលផ្ទុយទៅនឹងច្បាប់។ ឥឡូវនេះ ប្រសិនបើ អវតក ត្រូវបានគេមើលឃើញថាសំអាងទៅលើភស្តុតាងដែលជិតដាមដោយអំពើទារុណកម្ម ទោះបីជាដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នោះសាលាក្តីនេះនឹងបង្កើតបានឧទាហរណ៍ដែលមិនត្រឹមត្រូវ ដែលអាចមានឥទ្ធិពលអវិជ្ជមានទៅលើប្រព័ន្ធច្បាប់កម្ពុជានៅពេលអនាគត។

108. វាជាការសំខាន់បំផុតដែល អវតក កម្ពស់បទដ្ឋាននៃច្បាប់អន្តរជាតិ និងការការពារសិទ្ធិមនុស្សឱ្យបានខ្ពស់បំផុត។ រឿងក្តីព្រហ្មទណ្ឌនាពេលអនាគត នឹងសំអាងទៅលើឧទាហរណ៍ដែលកំណត់ដោយតុលាការនេះ។ ប្រសិនបើតុលាការនេះសំអាងទៅលើភស្តុតាង ដែលជាប់ជិតដាមដោយអំពើទារុណកម្ម ឱកាសទាំងឡាយនោះគឺថា ប្រព័ន្ធច្បាប់កម្ពុជានឹងអនុវត្តតាមនេះ និងអនុសញ្ញាតឱ្យមានសំអាងជាបន្តទៅទៀតទៅលើភស្តុតាង ដែលបានមកពីការប្រើប្រាស់អំពើទារុណកម្មដូចសព្វថ្ងៃនេះជាមិនខាន។

---

[75] ក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប ថ្ងៃទី ២៩ កុម្ភៈ ២០០៨, ឯកសារលេខ A/HRC/7/42 កថាខណ្ឌទី ២៤។

[76] នៅក្នុងចំណោមបញ្ហាជាច្រើន សូមមើលផងដែរ សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស "Cambodian League for Promotion and Defense of Human Rights" "អំពើទារុណកម្មនៅក្នុងមន្ទីរឃុំឃាំងរបស់នគរបាល" ចុះខែ មេសា ឆ្នាំ ២០០៣។ របាយការណ៍របស់ក្រសួងការបរទេសអាមេរិកស្តីពីកម្ពុជា ឆ្នាំ២០០៧ និង Freedom House "សេរីភាពនៅក្នុងពិភពលោក ឆ្នាំ ២០០៧"។

109. មេធាវីការពារក្តីសូមសំណូមពរឲ្យច្រានចោលភស្តុតាង ដែលបានដោយអំពើទារុណកម្ម ដោយមិនគិតពីភាពគួរឲ្យជឿជាក់បាន (ដែលនាំឲ្យមានទម្ងន់ទៅលើភស្តុតាងនោះ) ប៉ុន្តែ ដោយសារថា ការប្រើប្រាស់ភស្តុតាងបែបនេះ គឺគួរឲ្យស្អប់ខ្ពើមជាខ្លាំងក្នុងការធ្វើយុត្តិកម្ម និងអាចបង្កើតបានជាឧទាហរណ៍មួយដែលមិនត្រឹមត្រូវចំពោះប្រទេសមួយ ដែលការអនុវត្តន៍អំពើទារុណកម្មមិនបានលប់បំបាត់ចោលនៅឡើយនោះ។ ដោយសារហេតុផលទាំងអស់នេះ ត្រូវច្រានចោលដីកាសម្រេចនេះ។

110. បន្ថែមលើនេះទៅទៀត ក្រៅពីមានផលប៉ះពាល់ជាអវិជ្ជមានទៅលើសង្គមកម្ពុជា ការបកស្រាយមាត្រា១៥នៃអនុសញ្ញា CAT ក្នុងលក្ខណៈមួយផ្ទុយទៅនឹងគណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្ម នោះការបកស្រាយយុត្តាធិការអាចនាំឲ្យមានការបែកវែកនូវការបកស្រាយអនុសញ្ញានេះ ។ ចំនុចនេះអាចបើកចំហរជាជម្រើសសម្រាប់តុលាការកម្ពុជា និងតុលាការដទៃទៀតនៅជុំវិញពិភពលោក ក្នុងការបកស្រាយមាត្រានេះ ដើម្បីគាំទ្រដល់ជំហរណាមួយរបស់ពួកគេ ដូចដែលកសចស ស្នើសុំឲ្យមាននៅក្នុងរឿងក្តីពិសេសនេះ។ ចំនុចត្រង់នេះអាចប៉ះពាល់យ៉ាងខ្លាំងដល់មូលហេតុនៅពីខាងក្រោយមាត្រា ១៥ នៃអនុសញ្ញា CAT ។ ដោយសារតែមូលហេតុនេះផងដែរ នោះត្រូវតែច្រានចោលដីកាសម្រេចនេះ។

111. នៅពេលដែលសរសេរសារណាបណ្តឹងឧទ្ធរណ៍នេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានចេញសារណាមួយជូនអង្គបុរេជំនុំជម្រះក្នុងការដោះស្រាយជាមួយនឹងបញ្ហាជាក់លាក់នៃភាពត្រឹមត្រឹមនៃ អវតក នៅកម្ពុជា[77]។ មេធាវីការពារសូមបង្ហាញជូន នូវសារណានេះចំពោះបណ្តឹងឧទ្ធរណ៍នេះ។

## XVII. មូលហេតុទី ១២ នៃបណ្តឹងឧទ្ធរណ៍: ការអនុវត្តគោលការណ៍វិមតិសង្ស័យ

### "APPLICABILITY OF *IN DUBIO PRO REO*"

112. នេះជាគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហើយជាការពិត នៅក្នុងយុត្តាធិការជាតិជាច្រើនដែលថានៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រសិនបើមានវិមតិសង្ស័យ នោះការបកស្រាយបទប្បញ្ញត្តិច្បាប់ឲ្យបានត្រឹមត្រូវ គួរតែបានជាប្រយោជន៍ដល់ជនជាប់ចោទ។ គោលការណ៍នេះត្រូវបាន

[77] [77] CCHR, 'Application of the CCHR to Present an Amicus Curiae Submission Pursuant to Internal Rule 33 – Amicus Curiae Submission of the CCHR', 7 September 2009, available at: http://www.cchrcambodia.org/English/add_report/reports/cchr%20acb%20sept.%207(090709_1252307364).pdf

00374913



គេហៅថាគោលការណ៍ *in dubio pro reo* ដូចដែលបានលើកឡើងនៅក្នុងរឿងក្តី *Tadic* ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY បានលើកឡើងថា"នៅក្នុងការអនុវត្តន៍លក្ខខណ្ឌនេះ រាល់វិមតិសង្ស័យគួរវបានជាប្រយោជន៍ដល់ជនជាប់ចោទ ស្របតាមគោលការណ៍ *in dubio pro reo*[78]។

113. នៅក្នុងការបកស្រាយអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម ហើយជាពិសេសគឺមាត្រា ១៥ នៃអនុសញ្ញានេះ ការបកស្រាយបានជាប្រយោជន៍យ៉ាងច្រើនដល់ជនត្រូវចោទ ត្រូវតែយកមកប្រើ។ ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថា ការបកស្រាយដែលអះអាងដោយ កសចស ថាត្រឹមត្រូវ ដែលមិនអាចទទួលយកបាន នោះការបកស្រាយនោះមិនគួរយកមកអនុវត្តទេ ដោយសារតែវារំលោភទៅលើគោលការណ៍នេះ។ យោងទៅលើមូលដ្ឋាននេះផងដែរ ត្រូវច្រានចោលដីកាសម្រេចនេះ។

## XVIII. មូលហេតុទី ១៣ នៃបណ្តឹងឧទ្ធរណ៍: កសចស មិនមានសិទ្ធិបង្កើតច្បាប់ទេ

114. ហេតុដូច្នេះ កសចស បានកំណត់និយមន័យនៃទិសដៅ និងគោលបំណងរបស់អនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្មនេះឡើងវិញ។ ការសំអាងទៅលើគោលបំណងនៃអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម និងមាត្រា១៥ នៃអនុសញ្ញានេះ ដែលបានកំនត់និយមន័យដោយខ្លួនឯង គឺមានឥទ្ធិពលដល់ការផ្តល់ឆន្ទានុសិទ្ធិឲ្យតុលាការច្រើនពេក និងនាំឲ្យតុលាការនេះជាទាក់ទិនទៅនឹងការតាក់តែងច្បាប់ដោយតុលាការ (in judicial law-making)[79]។

115. គណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្មបញ្ជាក់ច្បាស់លាស់ហើយ ចំពោះការបដិសេធរបស់ខ្លួនមិនអនុសញ្ញាតឲ្យតុលាការមានឆន្ទានុសិទ្ធិច្រើនពេក នៅក្នុងការកំណត់ពីវិសាលភាពនៃមាត្រា ១៥ នៃអនុសញ្ញា CAT[80]។ តុលាការអាជ្ញាកណ្តាលអន្តរជាតិបានបញ្ជាក់ច្បាស់ថា ដំណើរការនៃការ

---

[78] រដ្ឋអាជ្ញា តទល់នឹង *Tadic*, IT-94-1-A, សេចក្តីសម្រេចទៅលើសារណារបស់ដើមបណ្តឹងឧទ្ធរណ៍ ក្នុងការស្នើសុំពន្យារពេលវេលាកំណត់ និងការទទួលយកភស្តុតាងបន្ថែមទៀត ចុះថ្ងៃទី ១៥ តុលា ១៩៩៨ កថាខណ្ឌទី ៧៣។

[79] M. Shaw, ច្បាប់អន្តរជាតិសាធារណៈ (២០០៣) ទំព័រទី ៨៣៩។

[80] CAT/C/CR/30/6 (2003), នៅក្រោមប្រធានបទ-គ ស្តីពី ការព្រួយបារម្ភ កថាខណ្ឌទី ៥ (ណ)។ សូមមើលផងដែរ CAT/C/SR.494, កថាខណ្ឌទី ៣៣ និង A/48/44, កថាខណ្ឌទី ១៤៨។

បកស្រាយ គឺជា "តួនាទីរបស់តុលាការដែលមានគោលបំណងកំណត់ន័យនៃបញ្ញត្តិច្បាប់ឱ្យច្បាស់លាស់ ប៉ុន្តែ មិនអាចផ្លាស់ប្តូរន័យបានទេ"[81]។

116. ទ្រឹស្តីនៃ *non liquet* (តាមន័យត្រង់ៗ "វាមិនច្បាស់លាស់") អនុញ្ញាតឱ្យចៅក្រមបំពេញចន្លោះប្រហោងច្បាប់ (judicial gaps) ក្នុងករណីដែលច្បាប់នោះមិនមានលក្ខណៈពេញលេញ[82]។ ប៉ុន្តែចំពោះករណីនៃមាត្រា ១៥ ច្បាប់នេះគឺពេញលេញគ្រប់ជ្រុងជ្រោយហើយ។ សេចក្តីថ្លែងរបស់ច្បាប់នេះគឺច្បាស់លាស់ និងគ្មានស្រពិចស្រពិលនោះឡើយ ហើយការបកស្រាយណាមួយផ្ទុយទៅនឹងអត្ថន័យដើមរបស់ច្បាប់នេះ គឺជាការផ្ទុយទៅនឹងច្បាប់។

117. ការបកស្រាយអនុសញ្ញា CAT និងមាត្រា១៥ ដែលមានចែងនៅក្នុងកថា ខណ្ឌទី ២១ កថាខណ្ឌទី ២៣ ដល់២៥ និងកថាខណ្ឌទី ២៨ នៃដីកាសម្រេចនេះ គឺមិនស្របទៅនឹងការបកស្រាយដែលទទួលស្គាល់ជាអន្តរជាតិ ដូចដែលបានកំណត់ដោយគណៈកម្មាធិ-ការប្រឆាំងនឹងអំពើទារុណកម្ម និងយុត្តាធិការជាតិដទៃទៀតនោះទេ។ ដោយការបង្កើតគោលបំណងថ្មីសម្រាប់អនុសញ្ញា CAT និងមូលហេតុថ្មីសម្រាប់មាត្រា ១៥ នៃអនុសញ្ញានេះ កសចស ជាប់ពាក់ព័ន្ធទៅនឹងការបង្កើតច្បាប់តាមផ្លូវតុលាការ ដែលជាទង្វើមួយត្រូវបានហាមឃាត់នៅក្រោមច្បាប់អន្តរជាតិ។ អាស្រ័យហេតុនេះ ត្រូវច្រានចោលសេចក្តីសម្រេចរបស់ កសចស។

## XVIII. មូលហេតុទី ១៤ នៃបណ្តឹងឧទ្ធរណ៍: ដីកាសម្រេចពុំមានហេតុផលគ្រប់គ្រាន់

118. ដីកាសម្រេច "ច្រានចោលសំណើរបស់មេធាវីការពារក្តី" ប៉ុន្តែ ក្នុងការច្រានចោលបែបនេះ កសចស ខកខានមិនបានបញ្ជាក់ឱ្យបានច្បាស់លាស់ ថាហេតុអ្វីបានជាការជំទាស់តវ៉ាជាមូលដ្ឋានដែលមេធាវីការពារក្តីបានលើកឡើង នៅក្នុងសំណើសុំ និងការឆ្លើយតបរបស់មេធាវីការពារក្តីត្រូវបានបដិសេធនោះ។ នេះគឺជាការរំលោភរបស់ កសចស ក្នុងការចេញសេចក្តីសម្រេចប្រកបដោយហេតុផល។

---

[81] តុលាការអាជ្ញាកណ្តាលអន្តរជាតិ, ករណីនៃប្រទេសអាហ្សង់ទីន (Argentina) តទល់នឹង ប្រទេសឈីលី ( Chile) Laguna del Desierto, សាលក្រមចុះថ្ងៃទី ២១ តុលា ១៩៩៤ ដែលបានយោងទៅលើ M. Shaw, *ច្បាប់អន្តរជាតិសាធារណៈ (២០០៣) ទំព័រទី ៨៤១។*

[82] M. Swart, ចៅក្រម និងការបង្កើតច្បាប់នៅតុលាការអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងប្រទេសរ៉ាន់ដា (២០០៦) ទំព័រទី ៦៧។

119. នៅក្នុងផ្នែក ៣.៧ នៃសំណើសុំរបស់មេធាវីការពារក្ដី (សិទ្ធិទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌) មេធាវីការពារក្ដីបានបញ្ជាក់ថា ការខកខានរបស់ កសចស ដើម្បីច្រានចោលភស្តុតាងដែលជិតដាមដោយអំពើទារុណកម្ម ពីសំណុំរឿង នាំឲ្យមានការរំលោភទៅលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌។ ផ្ទុយទៅវិញ ដីកាសម្រេចខកខានមិនបានបង្ហាញហេតុផលចំពោះការច្រានចោលទឡ្ហីករណ៍របស់មេធាវីការពារក្ដីនោះឡើយ។

120. សាលក្រមនីមួយៗរបស់តុលាការ ត្រូវផ្ដល់មូលហេតុសម្រាប់ការធ្វើសេចកក្ដីសម្រេច។ តុលាការសិទ្ធិមនុស្សអឺរ៉ុបយល់ឃើញថា វាជាគោលការណ៍ទូទៅរបស់ច្បាប់ ដូចបានកត់សំគាល់នៅក្នុងរឿងក្ដី *Hadjianastassiou តទល់ជាមួយប្រទេសក្រិច*

> តុលាការត្រូវតែ [...] បង្ហាញនូវមូលហេតុឲ្យបានគ្រប់គ្រាន់ នៅពេលពួកគេធ្វើសេចក្ដីសម្រេច។ ការធ្វើដូច្នេះ គឺដើម្បីផ្ដល់លទ្ធភាពឲ្យជនជាប់ចោទប្រើសិទ្ធិដ៏មានផលប្រយោជន ដើម្បីប្ដឹងឧទ្ធរណ៍ដែលគាត់អាចប្ដឹងបាន[83]។

121. លក្ខខណ្ឌតម្រូវនេះ គឺអនុវត្តស្មើគ្នាចំពោះដីកាសម្រេចនេះ ដែលត្រូវផ្ដល់មូលហេតុឲ្យគ្រប់គ្រាន់ ។ ដូចបញ្ជាក់រួចមកហើយ ដីកានេះមិនបានពន្យល់ថាហេតុអ្វីបានជាខ្លួនបដិសេធអំណះអំណាងអំពីការជំនុំជម្រះក្ដីដោយយុត្តិធម៌។ ដីកានេះក៏បានខកខានពន្យល់ថា ហេតុអ្វីខ្លួនបដិសេធការបកស្រាយនៃមាត្រា១៥ ដែលត្រូវបានទទួលស្គាល់ជាទូទៅ ដែលត្រូវបានអនុញ្ញាតដោយមាត្រា ១៥ នៃអនុសញ្ញា CAT និងដោយយុត្តិសាស្ត្រជាតិ និងអន្តរជាតិផងនោះ។ មេធាវីការពារសូមអះអាងដោយក្ដីគោរពថា ដីកាសម្រេចនេះមិនឆ្លើយតបនឹងលក្ខណ្ឌនេះទេ។

122. ហេតុដូច្នេះ ត្រូវបដិសេធដីកានេះ ហើយដាក់ជំនួសដោយសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

## XX សេចក្ដីសន្និដ្ឋាន

123. សម្រាប់មូលហេតុដូចបានលើកឡើងនៅនេះ មេធាវីការពារក្ដីសូមស្នើថា ដីការបស់ កសចស ត្រូវតែបដិសេធ។

---

[83] *Hadjianastassiou តទល់ជាមួយប្រទេសក្រិច* សេចក្ដីសម្រេចរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប, ពាក្យសុំលេខ 12945/87 ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩២ កថាខណ្ឌ ៣៣។

- អង្គបុរេជំនុំជម្រះមានយុត្តាធិការពិនិត្យលើបណ្តឹងឧទ្ធរណ៍ ដោយមូលហេតុការរំលោភសិទ្ធិរបស់ជនត្រូវចោទ ទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងដោយអនុលោមតាមវិធាន ៧៤(៣)(ខ) និងវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។
- មេធាវីការពារសូមបញ្ជាក់ថា មានមូលហេតុបណ្តឹងឧទ្ធរណ៍ចំនួន ១៤ ដែលមូលហេតុនីមួយៗផ្តល់នូវមូលដ្ឋានគ្រប់គ្រាន់ សម្រាប់បដិសេធដីកា។
- មេធាវីការពារស្នើឱ្យអង្គបុរេជំនុំជម្រះសម្រេចបដិសេធដីកានេះ និងដាក់ជំនួសដោយសេចក្តីសម្រេចរបស់ខ្លួនវិញ ។

## XXI សំណូមពរ

124. សម្រាប់មូលហេតុដូចបានលើកឡើងនៅនេះ មេធាវីការពារក្តីស្នើសុំឱ្យអង្គបុរេជំនុំជម្រះ៖ បដិសេធចោលដីការបស់ កសចស និង

ក. បង្គាប់បញ្ជា កសចស

មិនទទួលយកនូវភស្តុតាង ឬចម្លើយសារភាពទាំងឡាយណាដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ក្រៅតែពីការបង្ហាញឱ្យឃើញថា ចម្លើយសារភាពមួយចំនួនត្រូវបានធ្វើឡើងដោយការធ្វើទារុណកម្ម និងសម្រាប់តែប្រឆាំងនឹងអ្នកប្រព្រឹត្តអំពើទារុណកម្មតែប៉ុណ្ណោះ រួមទាំង តែមិនកំណត់ចំពោះតែឯកសារដូចខាងក្រោម:

- ឯកសារ D3/ឧបសម្ព័ន្ធ គ (ស-ចម្លើយសារភាព) ។
- ឯកសារ D82 (ឯកសារទូលស្លែង) ។
- ឯកសារ D43 (ឯកសាររបស់ DC-Cam)[84]។
- ភស្តុតាងជំនាញដែលសំអាងលើចម្លើយសារភាពទាំងនេះ ដូចជាឯកសារ D2/15 ដោយលោក Craig C. Etcheson ។

ខ. មិនប្រើប្រាស់ចម្លើយសារភាពបែបនេះទោះបីជាតាមវិធីណាក៏ដោយ ដែលមានចែងនៅក្នុងចំនុច (ក) ខាងលើ។

---

[84] Doc. No. D3, Annex C – Other Evidentiary Material, Document Index, ERN 00141524-00141652, relevant pages 13-28; Doc. No. D82, Rogatory Letter, 29 January 2008, ERN 00173193-00173194, and all Annexes and Reports of Rogatory Letters related to D82; and Doc. No. D43, Rogatory Letter, 7 December 2007, ERN 00156491-00156492, and all Annexes and Reports of Rogatory Letters related to D43.

| ភាគី | កាលបរិច្ឆេទ | ឈ្មោះរបស់មេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី១០ ខែ កញ្ញា ឆ្នាំ ២០០៩ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA |